IDEA BOOK

# មើលខ្សែបាតដៃ



## តាមក្បួនចិន



គ្រាន់តែឃើញ
ខ្សែបាតដៃ
ក៏អាចយល់បានថា
អ្នកជាមនុស្ស
បែបណា?

www.elibraryofcambodia.org

ទិញដោយចៅលោកឡៅ ឃុន សិទ្ធិសម្បត្តិកុលាបខ្មែរជឿថ្មី
ទុកដាក់ក្នុង elibrary of Cambodia កក្កដា 2015

# មើល

## ខ្សែបាតដៃតាមក្បួនចិន



www.elibraryofcambodia.org

## មើលខ្សែបាតដៃតាមក្បួនចិន

ប្រែសម្រួលដោយ **អ៊ុម លិញ**
ពិនិត្យអក្ខរាវិរុទ្ធដោយ **រស់ វាសនា និង យ៉ាន ហៀន**
កំណែកុំព្យូទ័រដោយ **ពូន សាមឿន**
រចនាទំព័រដោយ **អ៊ួង តាក់**
រចនាគម្របដោយ **សុង បូរ៉ា**
អ្នកទីផ្សារ និងចែកចាយសៀវភៅដោយ **លាស់ សុច័ន្ទ និង មឿន សុគីម**
រក្សាសិទ្ធិគ្រប់យ៉ាងដោយគ្រឹះស្ថានបោះពុម្ពផ្សាយ **IDEA BOOK**

ideabookcambodia@gmail.com
facebook.com/ideabookpublishing

បោះពុម្ពឆ្នាំ ២០១៣
ដោយ **Olympic Printing**

ISBN: 978999-6332-24-1

តម្លៃ : ៨ ០០០ រៀល

www.elibraryofcambodia.org

# សេចក្ដីផ្ដើម

បាតដៃនិងម្រាមដៃរបស់មនុស្សប្រកបដោយទ្រង់ទ្រាយផ្សេងប្លែកៗពីគ្នាដល់ទៅ១៧បន្ទះ និងមានសាច់ដុំទាំងធំទាំងតូចដល់ទៅ១៩ដុំដោយសារការវិវត្តដ៏ស្មុគស្មាញនេះហើយ ទើបធ្វើឲ្យមនុស្សក្លាយជាអ្នកសាងប្រវត្តិសាស្ត្រ។

ការទស្សន៍ទាយបាតដៃតាមរយៈខ្សែដៃ ចុងម្រាមដៃនិងស្នាមម្រាមដៃផ្ទុះបញ្ជាំងឲ្យឃើញនូវរឿងរ៉ាវយ៉ាងច្រើនទាក់ទងទៅនឹងឧបនិស្ស័យរបស់មនុស្សម្នាក់ៗទាំងអតីតកាលនិងអនាគតកាល ដែលអាចធ្វើឲ្យយើងយល់ដឹងកាន់តែច្រើននៅក្នុងជីវិត ដូចជា សុខភាព សម្ពន្ធភាព និងសតិបញ្ញាជាដើម។

ក្នុងសៀវភៅនេះក៏មានបង្ហាញដូចតទៅ ៖

- សេចក្ដីអធិប្បាយយ៉ាងលម្អិតទាក់ទងនឹងខ្សែទាំងអស់លើបាតដៃ រួមទាំងលក្ខណៈសំខាន់ៗលើដៃ
- បកស្រាយច្រើនជាង១៥០លក្ខណៈ ដោយឈរលើមូលដ្ឋានក្បួនបុរាណចិន
- រូបភាពងាយយល់

តាមរយៈការមើលស្នាមដៃ ធ្វើឲ្យងាយយល់ពីខ្លួនឯងនិងអ្នកដទៃបានយ៉ាងស្រួល។

គ្រឹះស្ថានបោះពុម្ព

www.elibraryofcambodia.org

# មាតិកា


| | |
|---|---|
| ដៃ | ៦ |
| វិធីមើលដៃ | ៨ |
| ប្រភេទដៃផ្សេងៗ | ៨ |
| ពកផ្សេងៗលើបាតដៃ | ៩ |
| ខ្សែផ្សេងៗលើបាតដៃ | ១២ |
| ខ្សែជីវិត | ១៣ |
| ខ្សែខួរក្បាលឬខ្សែសតិបញ្ញា | ២៣ |
| ខ្សែបេះដូង | ៣៤ |
| ខ្សែអាជីព | ៤៩ |
| ខ្សែស្នេហានិងអាពាហ៍ពិពាហ៍ | ៦១ |
| ខ្សែនៃភាពជោគជ័យ | ៦៥ |
| ខ្សែលុយ | ៦៨ |
| សញ្ញាលើបាតដៃ | ៦៩ |
| សញ្ញាផ្កាយ | ៧០ |
| សញ្ញាបីជ្រុង | ៧៤ |
| ខ្សែដេកឬខ្សែឈរជាច្រើននៅលើពកផ្សេងៗ | ៧៧ |
| សញ្ញាកាកបាទនៅលើពកព្រហស្បតិ៍ និងខ្សែក្រវាត់អង្គារ | ៨៣ |
| សញ្ញាបួនជ្រុងនៅលើបាតដៃ | ៨៤ |


www.elibraryofcambodia.org

ខ្សែគោលទាំងបួននៅលើបាតដៃមានលក្ខណៈប្រហាក់ប្រហែល
តួអក្សរ M ៨៤
ម្រាមដៃនិងម្រាមមេមានប្រភេទផ្សេងៗគ្នា ៨៥
ចុងម្រាមមានប្រភេទផ្សេងៗគ្នា ៨៦
ចង្អៀករវាងម្រាមដៃ ៨៨
ខ្សៅម្រាមដៃ ៩២
គន្លាក់ម្រាមដៃ ១០៨
ក្រចក ១១២
ខ្សែកដៃ ១១៨
អ្នកមានកេរ្តិ៍ឈ្មោះនិងបាតដៃរបស់ពួកគេ ១២២
ភាគបន្ថែម ១២៤

www.elibraryofcambodia.org

# ៦ ដៃ

**ខ្លឹមសារបង្រៀនវិជ្ជាមើលដៃរបស់ចិន**

នៅប្រទេសចិន ប្រពៃណីនៃការមើលដៃ ជាវិធីដ៏មានឥទ្ធិពល ដែលបង្ហាញពីភាពលម្អិតផ្សេងៗទាក់ទងនឹងបុគ្គលម្នាក់ៗ ដូចជាឧបនិស្ស័យ សុខភាព អតីតកាល និងអនាគតកាល។ ពេទ្យនិងអ្នកចិត្តវិទ្យាលោកខាងលិចខ្លះក៏បាននាំយកក្បួននេះទៅប្រើក្នុងពេលវិនិច្ឆ័យជំងឺដែរ។

អ្វីដែលបែងចែកភាពខុសគ្នារវាងក្បួនចិននិងក្បួនបស្ចិមប្រទេស គឺភេទ។ ក្នុងក្បួនចិនចាត់ទុកថា ដៃឆ្វេងសម្រាប់បុរស ចំណែកឯដៃស្តាំសម្រាប់ស្ត្រី ហើយប្រពៃណីក្បួនចិនប្រកាន់តាមគោលការណ៍ទៀតផង។ តាមបទពិសោធរបស់ខ្ញុំ រឿងនេះសំខាន់ខ្លាំងណាស់ ដោយសារខ្ញុំសង្កេតឃើញថាភេទស្រីនឹងល្អនៅដៃស្តាំ ខណៈដែលភេទប្រុសនឹងល្អលើដៃឆ្វេង។



www.elibraryofcambodia.org

នៅក្នុងសៀវភៅនេះខ្ញុំបានបង្ហាញការវិភាគប្រមាណ២០០ករណីទៅតាមមូលដ្ឋាននៅលើគោលនៃខ្សែទាំងប្រាំ និងពកទាំងប្រាំបីនៅលើបាតដៃ (ពកគឺ សាច់ផុះនៅលើបាតដៃដែលសំដៅដល់ឥទ្ធិពលដ៏ខ្លាំងក្លារបស់ផ្កាយព្រះគ្រោះ ដូចជាពកអង្គារ) រាល់សេចក្តីអធិប្បាយមានអមទៅដោយរូបភាពប្រការសំខាន់ដែលត្រូវចងចាំ គឺខ្សែទាំងនេះនឹងផ្លាស់ប្តូរទៅតាមអាយុនិងដំណើរជីវិត។ ដៃរបស់អ្នកមិនអាចលាក់បាំងអ្វីបានឡើយ ប៉ុន្តែជីវិតរបស់អ្នកមិនត្រូវបានជោគជតាកំណត់ទុកមុនទេ បើដៃរបស់អ្នកបង្ហាញពីខ្សែជីវិតក្នុងផ្លូវអវិជ្ជមាន អ្នករមែងធ្វើអ្វីមួយចំនួនទាក់ទងនឹងវាជានិច្ច ប៉ុន្តែបើយើងត្រៀមទុកមុន អាចគេចវេះពីការផ្លាស់ប្តូរនិងក្តីលំបាកផ្សេងៗបានទៀតផង។

ក្រោយពីសិក្សាស្រាវជ្រាវជាបន្តបន្ទាប់អស់រយៈពេលជាច្រើនឆ្នាំមក ខ្ញុំបានរកឃើញថា ភាគច្រើនមានឧបសគ្គរាំងស្ទះភាពរីកចម្រើនរបស់មនុស្សយើងជានិច្ច ឬយើងអាចហៅបានថា ជាការផ្លាស់ប្តូរដ៏ធំក្នុងពេលមានអាយុ ១៨, ៣០, ៤៥, ៥៥ និង៦៣ឆ្នាំ។ ចំណុចផ្លាស់ប្តូរក្នុងជីវិតទាំងនេះ មើលទៅហាក់ដូចជាសំខាន់ខ្លាំងណាស់។ ព្រហ្មលិខិតបានកំណត់យើងឲ្យប្រឈមនឹងបញ្ហាឬការផ្លាស់ប្តូរទាំងនេះរហូត ទោះបីចូលចិត្តឬមិនចូលចិត្តក៏ដោយ ប៉ុន្តែបើយើងត្រៀមខ្លួនទុកមុន យើងរមែងអាចរើបម្រាស់ចេញពីការផ្លាស់ប្តូរភាពអាក្រក់ៗឬក្តីលំបាកផ្សេងៗបានដោយងាយ។



www.elibraryofcambodia.org

# វិធីមើលដៃ



ប្រភេទដៃផ្សេងៗ

### ដៃទន់និងម៉ត់

សំដៅដល់មនុស្សដែលបានទទួលការចិញ្ចឹមបីបាច់ថ្នាក់ថ្នមច្រើន ដែលអាចឈានទៅរកភាពខ្ជិលប្រអូសនិងចូលចិត្តសម្ភារនិយម។ ពួកគេចង់បានសេចក្តីសុខក្នុងជីវិតដោយមិនយកចិត្តទុកដាក់នឹងសេចក្តីព្យាយាមអ្វីឡើយ។

### ដៃគ្រាស់និងឃើត

សំដៅដល់មនុស្សមានសិល្បៈប្រកបដោយបញ្ញា រឺឯចិត្តគំនិតជាអ្នកជំនួញទៀតផង។ ពួកគេដឹងពីវិធីឆ្ពោះទៅកាន់ភាពស្តុកស្តម្ភនិងភាពជោគជ័យ។



www.elibraryofcambodia.org

### ដៃតគ្រឹមនិងរឹង

ជាដៃរបស់មនុស្សដែលរីករាយនឹងធ្វើការងារពលកម្ម ពួកគេមានខ្សែជីវិតជាអ្នកប្រតិបត្តិ និងជាមនុស្សដែលមានគំនិតសាមញ្ញ ហើយរស់នៅដោយសុចរិតទៀងត្រង់។

### ដៃរឹងមាំនិងចង្អៀត




បង្ហាញដល់មនុស្សដែលមានចិត្តរឹងទទឹងខ្លាំង។ ពួកគេមានចិត្តរឹងមាំនិងភាពព្យាយាម ហើយធ្វើអ្វីៗគ្រប់យ៉ាងដើម្បីឲ្យសម្រេចគោលដៅ ថែមទាំងមានមហិច្ឆតាខ្ពស់ ហើយប្រកាន់ខ្ជាប់នូវគំនិតខ្លួនឯងជាចម្បង ដែលធ្វើឲ្យពួកគេមានសត្រូវយ៉ាងច្រើន។

### ពកផ្សេងៗលើបាតដៃ

ប្រជាជនចិនបានកំណត់ឈ្មោះផ្សេងៗរបស់បាតដៃមកពីគម្ពីរ អ៊ីជិង (គម្ពីរនៃការផ្លាស់ប្តូរ) ដូចតទៅនេះ កិន ចឹង ស៊ុន លី ស៊ីន ទុយ ផៀន និង ខាន់។ បរិវេណកណ្តាលបាតដៃហៅថា មិងថាំងឬភពអាទិត្យនិងចន្ទ។



www.elibraryofcambodia.org

## ឈ្មោះភពព្រះគ្រោះនៃពកផ្សេង

**គិន** សមស្របនឹងពកសុក្រ ដែលបង្ហាញដល់ការយល់ដឹងនិងការប្រតិបត្តិអ្វីៗគ្រប់យ៉ាង ដែលទាក់ទងនឹងភាពស្រស់ស្អាតនិងការពេញចិត្ត។ ពកដែលបង្ហាញដល់មនុស្សដែលមានទាំងសិល្បៈនិងការច្នៃប្រឌិត។




**ចិង** សមស្របទៅនឹងពកអង្គារទាប ដែលបង្ហាញដល់ការរាំងខ្លួនឯង ភាពអត់ធ្មត់ និងការការពារខ្លួនឯង។ បើពកនេះធំបង្ហាញដល់មនុស្សដែលមានការតស៊ូខ្ពស់។ បើពកនេះរាបស្មើ វាបង្ហាញដល់មនុស្សដែលសម្រេចចិត្តស្ទាក់ស្ទើរ។

**ស៊ុន**សមស្របនឹងពកព្រហស្បតិ៍ ដែលបង្ហាញដល់អំណាចនិងមហិច្ឆតា។ ពកនេះពេលវាធំ បង្ហាញដល់មហិច្ឆតានិងក្តីប្រាថ្នាដ៏ខ្លាំងក្លាដែលឆ្ពោះទៅរកភាពជោគជ័យក្នុងជីវិត។ បើវារាបស្មើ សំដៅដល់គុណសម្បត្តិផ្ទុយគ្នា។

**លី** សមស្របទៅនឹងពកសៅរ៍ ដែលបង្ហាញដល់សេចក្តីព្យាយាមសុភវិនិច្ឆ័យ និងគុណធម៌។ បើវាធំគឺបញ្ជាក់ដល់មនុស្សដែលមានហេតុផល


www.elibraryofcambodia.org

ប្រកាន់យកគោលការណ៍ និងធ្វើការច្រើន។ ពកសៅរ៍ដែលរាបស្មើបង្ហាញដល់គុណសម្បត្តិផ្ទុយគ្នា។

ក្នុងវិជ្ជាមើលបាតដៃរបស់ចិន ពកលីនៅក្រោមពកកណ្ដាលនិងពកនាង។

**ស៊ុន** សមស្របទាំងពកអាទិត្យនិងពកពុធ។ ពកអាទិត្យបង្ហាញដល់ការទទួលស្គាល់និងកេរ្តិ៍ឈ្មោះ បើពកអាទិត្យធំ ពួកគេនឹងទទួលបានជោគជ័យនិងមានកេរ្តិ៍ឈ្មោះច្រើន។ បើពកអាទិត្យរាបស្មើ វាសំដៅដល់គុណសម្បត្តិផ្ទុយគ្នា។ ពកពុធបង្ហាញដល់សតិបញ្ញា ភាពប្រែប្រួល និងការគិតដ៏ល្អក្នុងផ្លូវជំនួញ។ បើពកពុធធំ ពួកគេនឹងមានចិត្តជាអ្នកជំនួញ ហើយដឹងពីវិធីរកប្រាក់ដ៏សុចរិត។

**ទុយ** សមស្របនឹងពកអង្គារខ្ពស់ ដែលបង្ហាញដល់ភាពក្លាហាននិងគោលបំណងដ៏ខ្លាំងក្លា។ បើពកអង្គារខ្ពស់ធំ ពួកគេនឹងក្លាហាន ហើយដឹងថាខ្លួនឯងត្រូវការអ្វី។ បើពកអង្គារខ្ពស់រាបស្មើ វាបង្ហាញដល់ភាពកំសាកនិងការសម្រេចចិត្តមិនដាច់ស្រេច។

**ឆៀន** សមស្របនឹងពកចន្ទ ដែលបង្ហាញដល់អារម្មណ៍ ក្ដីស្រមៃ និងសមត្ថភាពក្នុងរឿងសម្ងាត់។ ពកចន្ទដែលធំ ជាលក្ខណៈរបស់មនុស្សដែលមានសមត្ថភាពពិសេសខាងផ្លូវចិត្ត។ ពកចន្ទដែលរាប បង្ហាញដល់មនុស្សដែលមិនស្គាល់ក្ដីស្រមៃឬគ្មានក្ដីស្រមៃ។

**ខាន់** សមស្របនឹងពកវរុណ ដែលជាផ្នែកមួយនៅក្រោមបាតដៃបំផុត បើពកវរុណធំ ពួកគេនឹងពូកែនិយាយ ចូលចិត្តចេញក្រៅផ្ទះ និងពូកែយល់ចិត្ត។

**មិងថាំង** សមស្របនឹងខ្សែក្រវាត់អង្គារ បើពកនេះធំ ពួកគេនឹងមានតុល្យភាពដ៏ល្អក្នុងជីវិត និងដឹងពីវិធីការពារខ្លួនឯងទៀតផង។



www.elibraryofcambodia.org

## ខ្សែផ្សេងៗលើបាតដៃ

យើងអាចដឹងពីអាយុរបស់ដើមឈើបានដោយការដឹងពីឆ្នាដាំវាដំបូងៗ ហើយដើមឈើមានជំងឺក៏ដឹងតាមរយៈពណ៌ខ្មៅជាំដែរ។ ដូច្នេះ យើងក៏អាចរកព័ត៌មានផ្សេងៗទាក់ទងនិងមនុស្សយើងបានតាមរយៈខ្សែបាតដៃផ្សេងៗ។ ព្រោះសារពាង្គកាយរបស់មនុស្សសាំញ៉ាំច្រើនជាងដើមឈើ ទើបមានខ្សែជាច្រើនលេចឡើងលើបាតដៃរបស់យើង។ ខ្សែនីមួយៗក៏មានគុណតម្លៃនិងអត្ថន័យរបស់វាទាំងអស់ ហើយទិន្នន័យស្ទើរតែទាំងអស់សុទ្ធតែប្រមូលផ្តុំដោយក្រុមគ្រូទាយ ឬសូម្បីតែគ្រូពេទ្យក៏ចាប់អារម្មណ៍ក្នុងក្បួននេះដែរ។




រូបភាពខាងលើនេះគឺខ្សែបាតដៃដ៏សំខាន់បំផុតដែលលេចឡើង វាបង្ហាញដល់បុគ្គលិកលក្ខណៈនៃគុណភាពជីវិតក្នុងពេលបច្ចុប្បន្នរបស់អ្នក ហើយអ្វីដែលសំខាន់បំផុតគឺអនាគតរបស់អ្នក។ សូមចងចាំទុកថា បើជាបុរស ប្រជាជនចិនពិនិត្យដៃឆ្វេង បើជាស្ត្រី នឹងពិនិត្យដៃស្តាំ។



www.elibraryofcambodia.org

## ខ្សែជីវិត

ខ្សែនេះបង្ហាញដល់ជីវិតរស់នៅយើនយូរ ជីវិតមានថាមពល និងជីវិតមានគុណភាព។ ខ្សែដែលច្បាស់និងវែង បង្ហាញដល់រាងកាយដែលមានសុខភាពល្អនិងអាយុវែង។ ខ្សែដែលពេញនិងជារង្វង់មូល បង្ហាញដល់មនុស្សដែលពោរពេញដោយថាមពល។ ខ្សែដែលព្រាលបង្ហាញដល់មនុស្សដែលខ្ជិលច្រអូសនិងមិនយកចិត្តទុកដាក់លើការងារ។



ទោះជាខ្ញុំបានអធិប្បាយទៅក្តី អ្វីៗគ្រប់យ៉ាងសុទ្ធតែផ្លាស់ប្តូរបាន។ បើអ្នកចាប់ផ្តើមយកចិត្តទុកដាក់លើការងារកាន់តែច្រើន ខ្សែនេះក៏នឹងច្បាស់និងជារង្វង់មូលច្រើនឡើង។ បើខ្សែដាច់ពីគ្នា អ្នកក៏ត្រូវចាប់អារម្មណ៍ទៅលើវិធីជីវិតរបស់អ្នកឲ្យបានច្រើនឡើង ព្រោះវាអាចនឹងមានលក្ខណៈហួសហេតុពេក ហើយអ្នកអាចនឹងជួបប្រទះរឿងរ៉ាវផ្លូវអវិជ្ជមានមួយចំនួននៅក្នុងជីវិត។ ដូច្នេះសូមមេត្តាប្រយ័ត្នឲ្យបានច្រើន។



www.elibraryofcambodia.org



**ពោរពេញទៅដោយ**
**កម្លាំងនិងថាមពលខាងផ្លូវភេទ**

បង្ហាញដល់ខ្សែជីវិតដ៏រឹងមាំនិងច្បាស់ណាស់។



**មិនចេះនៅស្ងៀម**
ខ្សែជីវិតចាប់ពីចុងបំផុតចុះមកលើពកចន្ទ គឺបង្ហាញដល់មនុស្សដែលមិនចេះនៅស្ងៀម និងជាមនុស្សដែលផ្លាស់ប្តូរ ដែលយកជាការមិនបាន ហើយច្រើនតែផ្លាស់កន្លែងជានិច្ច។ មនុស្សប្រភេទនេះជាអ្នកប្រថុយនឹងគ្រោះថ្នាក់ ព្រោះមានបំណងប្រាថ្នាចង់ធ្វើដំណើរជុំវិញពិភពលោក។



www.elibraryofcambodia.org

## សុខភាពមិនល្អនិងកាន់តែធ្ងន់ធ្ងរទៅៗ



ខ្សែជីវិតដែលខ្លី កោង និងចុងបំផុតចុះត្រង់ពកចឹង (ពកអង្គារទាប) ជានិមិត្តសញ្ញាមិនល្អ នេះជារឿងដែលត្រូវយកចិត្តទុកដាក់។ ពួកគេគួរតែទៅជួបគ្រូពេទ្យ។

## សុខភាពមិនល្អ



ខ្សែជីវិតដែលប្រកបដោយខ្សែតូចនិងខ្សែធំជាច្រើន គឺបញ្ជាក់ដល់សុខភាពខ្សោយ ហើយសួតមានដំណើរការមិនល្អទេ។



www.elibraryofcambodia.org



## មានជំងឺតម្កាត់ តែក៏អាចងើបពីសភាពនោះបានដែរ

ខ្សែជីវិតដែលដាច់ តែនៅគងគ្នារយៈខ្លីៗ បង្ហាញដល់សុខភាពមិនល្អ ប៉ុន្តែក៏អាចគេចផុតពីស្ថានភាពនោះបានដែរ គ្រាន់តែត្រូវយកចិត្តទុកដាក់ទៅលើសុខភាពរបស់ខ្លួន និងប្រញាប់បំប៉នសុខភាពឲ្យប្រសើរឡើងបានយ៉ាងឆាប់រហ័សទៀតផង។



## ឆ្មាជីវិតប្រាំបួន

ពេលខ្សែជីវិតដាច់ រឺតផ្នែកដែលគងលើគ្នាមានសញ្ញាបួនជ្រុង គឺបង្ហាញដល់ឧប្បត្តិហេតុជាច្រើនផង។ ទោះជាយ៉ាងណាក៏ដោយ សញ្ញានេះនឹងចាំការពារគេ រហូតធ្វើឲ្យគេប្រៀបដូចជាឆ្មាមានជីវិតប្រាំបួនអ៊ីចឹង។



www.elibraryofcambodia.org

**សុខភាពយ៉ាប់យ៉ឺន ជាពិសេសប្រព័ន្ធការពារមានកម្រិតទាប**



ខ្សែជីវិតដែលមានលក្ខណៈ ដូចជា សញ្ញាកាកបាទតភ្ជាប់ជាខ្សែអង្កាញ់។ ជាសញ្ញាដ៏គ្រោះថ្នាក់បំផុត ដែលបង្ហាញដល់សុខភាពទន់ខ្សោយ។ មនុស្សដែលមានខ្សែជីវិតបែបនេះ នឹងឆាប់គ្រុន ហើយមានបញ្ហាសុខភាពច្រើន ទោះជាយ៉ាងណាក៏ដោយ ពួកគេក៏អាចពង្រឹងប្រព័ន្ធការពារបានផងដែរ ដោយការបរិភោគចំណីអាហារល្អៗ ហាត់ប្រាណជាប្រចាំ និងគេងឲ្យបានច្រើន។

**អាចនឹងកើតឧប្បត្តិហេតុពេលធ្វើដំណើរ**



ខ្សែជីវិតដែលដាច់គ្នាមិនមែនជាសញ្ញាដ៏ល្អឡើយ។ អ្វីដែលសំខាន់ គឺមិនត្រូវប្រមាទ ហើយកុំធ្វើដំណើរឆ្ងាយពេក ព្រោះអាចមានឧប្បត្តិហេតុផ្សេងៗ ប៉ុន្តែបើពួកគេប្រយ័ត្នប្រយែងបំផុត ក៏អាចផុតពីវាបានដែរ។



www.elibraryofcambodia.org

## សុខភាពយ៉ាប់យ៉ឺនដែលទាក់ទងនឹងក្បាលដោយផ្ទាល់



មានសញ្ញាកូនកោះនៅចំកណ្តាលខ្សែជីវិត និងមានខ្សែឆ្លងកាត់ខ្សែខួរក្បាល គឺបង្ហាញពីសុខភាពដែលយ៉ាប់យ៉ឺន ជាពិសេសបញ្ហាទាក់ទងនឹងក្បាល។ ទោះបីជាយ៉ាងណាក៏ដោយ ការបរិភោគចំណីអាហារល្អៗ និងការហាត់ប្រាណរាល់ថ្ងៃ នឹងធ្វើឲ្យសុខភាពត្រឡប់មកជាល្អដូចដើមវិញ។

## មានកង្វល់ទាក់ទងនឹងមនុស្សជាទីស្រឡាញ់



សញ្ញាកូនកោះដែលនៅជិតខ្សែជីវិតដែលលេចឡើង និងមានខ្សែតូចៗកាត់តាមខ្សែជីវិតយ៉ាងច្បាស់ គឺបង្ហាញដល់ការព្រួយបារម្ភចំពោះមនុស្សជាទីស្រឡាញ់។ អ្នកនឹងគិតច្រើនទាក់ទងនឹងបុគ្គលនោះ ហើយអាចធ្វើឲ្យខ្លួនឯងមានសុខភាពមិនល្អទៀតផង។



www.elibraryofcambodia.org

ជំងឺតម្កាត់

ពេលមានខ្សែតូចមួយឆ្លងកាត់តាមខ្សែជីវិត ហើយទេរទៅត្រង់ពកចន្ទ វាជាសញ្ញាបញ្ជាក់ថា សុខភាពទន់ខ្សោយ ដែលអាចមានបញ្ហាទាក់ទងនឹងថ្នាំញៀន។



សោកសៅនិងមិនគង់វង្ស

ខ្សែមិនធម្មតាមួយចំនួនលេចឡើងលើពកសុក្រ បង្ហាញថាគ្មានសេចក្ដីសុខនិងខ្វះទ្រព្យសម្បត្តិ។ ពួកគេមានអារម្មណ៍ថា ខ្លួនឯងខ្វះអ្វីមួយ ហើយផែនការច្រើនយ៉ាងរបស់ពួកគេ មិនសម្រេចតាមការរំពឹងទុក។





www.elibraryofcambodia.org

## សមត្ថភាពផ្លូវភេទប្រែប្រួលនិងខ្វះចំណាប់អារម្មណ៍ខាងផ្លូវភេទ




ពេលខ្សែជីវិតមានរាងដូចអក្សរអា (A) និងមានខ្សែមួយទៀតរត់ពីចំណុចនេះទៅរកចុងពកអង្គារទាប គឺបង្ហាញដល់ការអសមត្ថភាពផ្លូវភេទ បើនៅមានខ្សែតូចៗជាច្រើនឆ្លងកាត់ខ្សែជីវិតទៀតនោះ ពួកគេនឹងអស់ចំណង់ផ្លូវភេទតែម្តង។

## ធ្វើបាបខ្លួនឯងនិងអាចឈានដល់ការធ្វើអត្តឃាត



មានសញ្ញាកូនកោះលេចឡើងនៅក្បែរខ្សែជីវិត។ នេះជាលក្ខណៈនៃការធ្វើបាបខ្លួនឯងនិងមានគំនិតចង់ធ្វើអត្តឃាត ហើយវាជាលក្ខណៈរបស់មនុស្សដែលងាយធ្លាក់ក្នុងភាពសោកសៅ ដែលអាចធ្វើឲ្យកើតនូវគំនិតចង់ធ្វើអត្តឃាត។ គួរតែប្រយ័ត្នប្រយែងនៅពេលពួកគេនៅតែម្នាក់ឯង។



www.elibraryofcambodia.org

## គ្មានសេចក្តីសុខ

ពេលមានខ្សែមួយលេចឡើងនៅត្រង់ខ្សែជីវិតលើពកអង្គារទាប គឺបង្ហាញពីការស្រឡាញ់នរណាម្នាក់ ដែលមិនអាចតបស្នងដោយអារម្មណ៍តែម្យ៉ាង។ សម្ពន្ធភាពបែបនេះ ហាក់ដូចជាលើសពីកម្លាំង និងពិបាករក្សាណាស់។



## ការបែកគ្នាដោយមិនពេញចិត្ត

ពេលមានផ្កាយមួយលេចឡើងបន្ទាប់ពីខ្សែជីវិត និងមានខ្សែមួយទៀតតភ្ជាប់នឹងផ្កាយនិងសញ្ញាកូនកោះនៅលើខ្សែខួរក្បាល បុគ្គលនោះនឹងត្រូវបែកពីមនុស្សជាទីស្រឡាញ់របស់ខ្លួនដោយក្តីសោកសៅ។





www.elibraryofcambodia.org

## ស្នេហាដែលគ្មានសេចក្ដីសុខ



ខ្សែខ្លីៗដែលនៅជាប់ខ្សែជីវិតលើពកសុក្រ បញ្ជាក់ដល់ស្នេហាដែលគ្មានសេចក្ដីសុខឬស្នេហាដែលកំពុងមកដល់ចំណុចបញ្ចប់។

## ស្នេហាដែលមានសេចក្ដីសុខ



ខ្សែដែលស្របនឹងខ្សែជីវិត ជាលក្ខណៈដ៏ល្អ។ គេសង្ឃឹមថា នឹងបានទទួលក្ដីស្រឡាញ់យ៉ាងច្រើន និងមានសម្ពន្ធភាពដ៏ល្អជាមួយនឹងគូគ្រងរបស់ខ្លួន។



www.elibraryofcambodia.org



ខ្សែខួរក្បាលឬខ្សែសតិបញ្ញា

ខ្សែនេះបង្ហាញដល់ហេតុផល សតិបញ្ញា ការចងចាំ សមត្ថភាពខាងសិល្បៈ និងសមត្ថភាពក្នុងការប្រតិបត្តិ។ កាលណាខ្សែនេះកាន់តែច្បាស់ អ្នកក៏កាន់តែមានសតិបញ្ញាច្រើន ហើយបើខ្សែខួរក្បាលកាត់កែងនឹងខ្សែជីវិត គេក៏កាន់តែមានសមត្ថភាពក្នុងការប្រតិបត្តិច្រើនឡើង។ ខ្សែដេកបង្ហាញដល់មនុស្សមានបញ្ញាធម្មតា ចំណែកខ្សែទេរទៅរកពកចន្ទ បញ្ជាក់ពីមនុស្សដែលមានបញ្ញាល្អ។ ខ្សែខួរក្បាលដែលចូលជាមួយនឹងខ្សែបេះដូង បញ្ជាក់ថា •អ្នកជាមនុស្សដែលមានគំនិតច្នៃប្រឌិតច្រើន។

តទៅនេះជាការវិភាគលក្ខណៈរបស់ខ្សែខួរក្បាលនិងអត្ថន័យ



www.elibraryofcambodia.org

## សតិបញ្ញាខ្ពស់



បង្ហាញអំពីលក្ខណៈនៃសតិបញ្ញាដ៏ឈ្លាសវៃ និងមានគោលបំណងដ៏ខ្លាំងក្លា។ មនុស្សដែលមានខ្សែខួរក្បាលតភ្ជាប់ទៅនឹងខ្សែបេះដូងបែបនេះ ជាមនុស្សដែលមានជីវិតដើរឆ្ងាយ។ ជាពិសេស បើគេស្គាល់វិធីប្រើសមត្ថភាពរបស់ខ្លួនឲ្យមានប្រយោជន៍។ ផ្ទុយទៅវិញ គេងាយនឹងទទួលអារម្មណ៍មិនល្អ ឆាប់មានបញ្ហារឿងស្នេហា និងស្អប់នរណាម្នាក់។ គេចាំបាច់ត្រូវអភិវឌ្ឍភាពអត់ធ្មត់ឲ្យបានច្រើន។

## លោភនិងគ្មានសន្ដោស



ខ្សែខួរក្បាលដែលរត់ត្រង់មករកបេះដូង បញ្ជាក់ដល់មនុស្សដែលគ្មានចិត្ត គ្មានបេះដូង និងនិយមសម្ភារៈ។ គេសុខចិត្តធ្វើអ្វីគ្រប់យ៉ាងដើម្បីប្រាក់ ដូច្នេះគេគួរតែរៀនធ្វើចិត្តឲ្យបានទូលាយ និងយល់ចិត្តអ្នកដទៃឲ្យកាន់តែច្រើនឡើង។



www.elibraryofcambodia.org

## ស្រឡាញ់សេរីភាពតែជាមនុស្សរឹងរូស



ខ្សែខួរក្បាលដែលនៅឃ្លាតពីខ្សែជីវិត បញ្ជាក់ដល់មនុស្សដែលចូលចិត្តទប់ទល់និងបញ្ហាផ្សេងៗ ដោយវិធានការរបស់ខ្លួនឯង។ ពេលខ្លះ គេក៏ចាត់ការបានល្អ ពេលខ្លះក៏មិនសូវបានល្អដែរ។ ប៉ុន្តែអ្វីដែលសំខាន់សម្រាប់គេគឺស្វែងរកជំនួយនិងព្រមទទួលយកជំនួយ ព្រោះវានឹងធ្វើឲ្យជីវិតរបស់គេកាន់តែមានភាពងាយស្រួលប្រសើរឡើង។

## ជឿជាក់លើខ្លួនឯងយ៉ាងខ្លាំង



ខ្សែខួរក្បាលដែលនៅជិតខ្សែជីវិត បញ្ជាក់ដល់សេរីភាព។ការមើលពិភពលោកក្នុងគំនិតល្អ និងភាពជឿជាក់លើខ្លួនឯង ធ្វើឲ្យគេសម្លឹងបានវែងឆ្ងាយ។



www.elibraryofcambodia.org



## ចាស់មុនវ័យ

ដៃដែលមានសញ្ញាកូនកោះកើតឡើងនៅចុងខ្សែខួរក្បាល សំដៅដល់មនុស្សដែលមានអារម្មណ៍ថា ខ្លួនចាស់ជាងវ័យ ហើយគេឆាប់ចាស់ទៀតផង។ កំហឹងនិងកង្វល់ជាមូលហេតុនៃគំនិតអវិជ្ជមាន។



## ស្ទាក់ស្ទើរក្នុងការសម្រេចចិត្ត

ខ្សែខួរក្បាលដែលតភ្ជាប់នឹងខ្សែជីវិត បញ្ជាក់ដល់ភាពប្រែប្រួល។ លក្ខណៈបែបនេះ ច្រើនតែកើតឡើងលើបាតដៃមនុស្សស្រី ដែលពិបាកបែងចែកហេតុ-ផលចេញពីអារម្មណ៍។



www.elibraryofcambodia.org

## ជឿជាក់លើខ្លួនឯងខ្លាំង



ខ្សែខួរក្បាលបែងចែកជាពីរទិសដៅ មួយបែកទៅកាន់ពកអាទិត្យឬពកពុធ មួយទៀតទេរទៅកាន់ពកចន្ទ។ នេះក៏ជាលក្ខណៈនៃភាពជឿជាក់លើខ្លួនឯងយ៉ាងខ្លាំងដែរ។ វាបង្ហាញដល់មនុស្សដែលពូកែរៀបចំគម្រោងនិងរៀបចំក្រុម រួមទាំងមានសមត្ថភាពផ្លាស់ប្តូរគំនិតផ្សេងៗ ឲ្យក្លាយជាការប្រតិបត្តិ។

## បានទទួលការរាប់អាននិងមានកេរ្តិ៍ឈ្មោះខ្លាំង



ខ្សែដ៏ច្បាស់មួយដែលបែកចេញពីខ្សែខួរក្បាលឆ្ពោះទៅកាន់ម្រាមចង្អុលឬពកព្រហស្បតិ៍ បញ្ជាក់ដល់មនុស្សដែលបានទទួលការគោរពរាប់អានយ៉ាងខ្លាំង។ គេមានសមត្ថភាពអាចស្វែងរកភាពជោគជ័យក្នុងការងារបាន។



www.elibraryofcambodia.org

## ឧស្សាហ៍ព្យាយាម



ខ្សែខួរក្បាលដែលចែកជាពីរទិស ដៅ មួយបែកទៅកាន់ខ្សែបេះដូង និងមួយទៀតទេរបន្តិច គឺជាលក្ខណៈរបស់មនុស្សដែលដឹងខុសដឹងត្រូវ។ គេជាមនុស្សយកចិត្តទុកដាក់លើការងារជាខ្លាំង ហើយធ្វើអ្វីផ្សេងៗប្រកបដោយជោគជ័យ។

## នៅមិនស្ងៀម ព្រោះខុសគោលបំណង



ខ្សែខួរក្បាលដែលមានលក្ខណៈដូចសញ្ញាកាកបាទតភ្ជាប់គ្នាជាអង្កាញ់ៗ បង្ហាញដល់មនុស្សដែលមិននឹងន និងមិនជឿជាក់លើខ្លួនឯង។ គេជាមនុស្សមិនស្គាល់ខ្លួនឯង ដោយសារមិនអាចសម្រេចចិត្តបាន ហើយចូលចិត្តបណ្តោយជីវិតទៅតាមព្រេងវាសនា ប៉ុន្តែគេអាចដោះស្រាយសភាពដូច្នេះបាន ដោយការព្យាយាមផ្លាស់ប្តូទស្សនៈនិងវិធីគិតរបស់ខ្លួន។



www.elibraryofcambodia.org

## ចាប់អារម្មណ៍ស្នាដៃនិងការតែងនិពន្ធ



ពេលខ្សែខួរក្បាលបែកចេញពីគ្នាត្រង់ចំណុចសនៅចំកណ្តាលខ្សែ នេះជាលក្ខណៈរបស់អ្នកកាសែត អ្នកនិពន្ធអាជីពដែលទទួលបានជោគជ័យខ្លាំង ឬមានស្នាដៃច្រើន។

## សតិបញ្ញាខ្សោយនិងខ្វះគំនិតត្រឹមត្រូវ



ខ្សែខួរក្បាលដែលខ្លី បង្ហាញដល់មនុស្សដែលមានកម្រិតសមត្ថភាពខាងសតិបញ្ញាទាប។ នេះអាចមានមូលហេតុមកពីការឈឺចាប់របស់ម្តាយ ឬប្រើវិធីមានគ្រោះថ្នាក់ដល់សុខភាពក្នុងពេលមានផ្ទៃពោះ។



www.elibraryofcambodia.org

## ទទួលបានជោគជ័យនិងព្រមទទួលស្គាល់



ខ្សែដែលកើតឡើងត្រង់ខ្សែខួរក្បាល ឆ្ពោះទៅកាន់ពកស៊ីន (ពកពុធ) ក្រោមម្រាមកូនដៃ ជាលក្ខណៈរបស់មនុស្សដែលឧស្សាហ៍ព្យាយាមនិងមានសក្តានុពលឆ្ពោះទៅរកភាពស្ងុកស្តម្ភនិងកេរ្តិ៍ឈ្មោះ។

## ខ្សែជាច្រើនដែលនៅជាប់នឹងខ្សែខួរក្បាល



ខ្សែនៅលើខ្សែខួរក្បាល (A) បង្ហាញថា ជាមនុស្សមានសេដ្ឋកិច្ចល្អ ហើយផ្នែកអាជីពមានដំណើរការទៅមុខយ៉ាងរលូន។ ខ្សែតូចៗក្រោមខ្សែខួរក្បាល (B) និងត្រង់ចុងខ្សែខួរក្បាល (C) មានលក្ខណៈក្នុងផ្លូវអវិជ្ជមាន បញ្ជាក់ដល់ភាពជោគជ័យដែលមិនសូវល្អនិងមានសុខភាពយ៉ាប់យ៉ឺន។ មនុស្សដែលមានខ្សែខួរក្បាលបែបនេះ គួរសម្រាកនិងយកចិត្តទុកដាក់រាងកាយ បិត្តគំនិតឲ្យបានច្រើន។



www.elibraryofcambodia.org

### ឈឺក្បាលម្ខាង

ខ្សែខួរក្បាលដែលបែងចែកជាខ្សែតូចៗល្អិតៗ បង្ហាញដល់អាការៈឈឺក្បាលឬឈឺក្បាលម្ខាង ថែមទាំងបង្ហាញដល់ការខ្វះគំនិតឬគោលដៅនានាក្នុងជីវិតទៀតផង។



### មានសេចក្តីសុខនិងសប្បាយចិត្ត

ខ្សែខួរក្បាលដែលគងលើខ្សែជីវិតក្នុងកម្រិតទាបបំផុត បញ្ជាក់ដល់មនុស្សដែលមានមន្តស្នេហ៍ និងលះបង់ខ្លួន ហើយគេជាមនុស្សដែលយកចិត្តទុកដាក់ចំពោះតួនាទី គ្មានអារម្មណ៍តានតឹង ហើយងាយចុះ-សម្រុងនឹងអ្នកដទៃ។





www.elibraryofcambodia.org



## សតិបញ្ញាទាបខ្វះសមាធិ

ពេលខ្សែខួរក្បាលមានលក្ខណៈបែបនេះ បញ្ជាក់ដល់ការខ្វះសមាធិនិងកម្រិតសតិបញ្ញាទាប។ ទោះជាយ៉ាងណាក៏ដោយ ការហ្វឹកហាត់អប់រំឲ្យម៉ត់ចត់នឹងអាចយកឈ្នះបញ្ហាទាំងនេះបាន។



## មានស្នេហាមិនជាទីគាប់ចិត្ត

ខ្សែខួរក្បាលត្រួតគ្នា បង្ហាញដល់ការមិនពេញចិត្តទៅលើសម្ពន្ធភាពពីមួយទៅមួយ ហើយអាចពាក់ព័ន្ធនឹងបុគ្គលទីបី គឺស្នេហាត្រីកោណដែលអាចបង្កឲ្យកើតជាបញ្ហាពិបាកនិងភាពរកាំរកូស។



www.elibraryofcambodia.org

## ខ្ទិលច្រអូសនិងមាន មានៈបន្តិចបន្តួច



ពេលដែលខ្សែខួរក្បាលទេរចុះបែបនេះ បង្ហាញដល់មនុស្សដែលចាប់ផ្តើមធ្វើអ្វីគ្រប់យ៉ាងបានល្អ ប៉ុន្តែខ្វះភាពអត់ធ្មត់ក្នុងការធ្វើការងារនោះឲ្យបានជោគជ័យ។ ពេលមានបញ្ហាកើតឡើង គេច្រើនតែខ្ជិលច្រអូស និងខ្វះភាពជឿជាក់លើការងារ។

## ចិត្តគំនិតរបស់អ្នកជំនួញ



ខ្សែខួរក្បាលដែលបែងចែកដូចនេះ បញ្ជាក់ដល់មនុស្សដែលមានសមត្ថភាពខ្ពស់ក្នុងការសម្រេចគោលដៅក្នុងជីវិត ហើយមិនបាច់ឆ្ងល់នោះទេដែលពួកគេមានភាពឈ្លាសវៃខាងជំនួញ ព្រមទាំងមានស្តុកស្តម្ភ និងទទួលជោគជ័យទៀតផង។



www.elibraryofcambodia.org



## ខ្សែបេះដូង

ខ្សែនេះបង្ហាញដល់អារម្មណ៍និងសម្ពន្ធភាព ដូចជាសុខភាពផ្លូវកាយ។ ខ្សែបេះដូងដែលវែងនិងច្បាស់ បញ្ជាក់ដល់មនុស្សដែលមានសេចក្តីស្រឡាញ់ពិតប្រាកដ ស្មោះត្រង់ និងគួរឲ្យជឿជាក់បាន។ ខ្សែបេះដូងព្រាលៗបង្ហាញដល់មនុស្សទន់ខ្សោយ ចំណែកខ្សែបេះដូងខ្លី (វែងមិនដល់បរិវេណក្រោមម្រាមនាង) បង្ហាញដល់មនុស្សដែលស្ពឹកស្រពន់និងស្រឡាញ់សេរីភាព។ អ្នកដែលស្រឡាញ់សេរីភាពជាច្រើនមានខ្សែបែបនេះ។ ខ្សែបែកខ្នែងលើខ្សែបេះដូងបង្ហាញដល់ការកើតរឿងរំភើបចិត្ត ចំណែកខ្សែបែកខ្នែងក្រោមខ្សែបេះដូងបង្ហាញដល់បទពិសោធអវិជ្ជមានទាក់ទងនឹងរឿងស្នេហា សេចក្តីប្រាថ្នា ខ្សែបេះដូងដែលមានខ្សែតូចៗរត់កាត់ បង្ហាញដល់មនុស្សមិនស្មោះត្រង់ ខ្សែបេះដូងដែលមានលក្ខណៈប្រែប្រួល ប្រាកដឡើងជារណ្តៅច្រើនកន្លែង បង្ហាញដល់បេះដូងដែលទន់ខ្សោយ។ បើខ្សែបេះដូងរបស់អ្នកមានលក្ខណៈដូច្នេះអ្នកគួរប្រយ័ត្នប្រយែងការផឹកស៊ី គួរចៀសវាងអាហារដែលមានកូលេស្តេរ៉ូល (Cholesterol) ខ្ពស់ និងគួរប្រឹក្សាជាមួយនឹងពេទ្យអំពីចលនាឈាមផង។



www.elibraryofcambodia.org

## តទៅនេះ គឺការវិភាគលក្ខណៈខ្សែបេះដូងនិងអត្ថន័យ

### ស្រឡាញ់ពិតប្រាកដនិងយូរអង្វែង



ពេលខ្សែខួរក្បាលឡើងទៅរកពកព្រហស្បតិ៍ត្រង់ក្រោមម្រាមចង្អុល បញ្ជាក់ថា ជាមនុស្សស្មោះត្រង់និងមានសេចក្ដីស្រឡាញ់ពិតប្រាកដ។ មនុស្សបែបនេះ ច្រើនតែស្វែងរកក្ដីស្រឡាញ់ដ៏ស៊ីជម្រៅនិងមានគោលបំណងដ៏ជាក់លាក់ទៀតផង។

### គ្មានអារម្មណ៍រំភើប



ខ្សែបេះដូងដែលខ្លីខ្លាំងជាលក្ខណៈរបស់មនុស្សដែលស្ពឹកស្រពន់និងពូកែគិត។ មនុស្សបែបនេះ មិនយល់អំពីក្ដីស្រឡាញ់នោះទេ (ទោះបីជាពួកគេអាចផ្លាស់ប្ដូរ ទស្សនៈបានក៏ដោយ) ហើយមានបំណងប្រាថ្នាខ្ពស់និងស្រឡាញ់សេរីភាពទៀតផង។



www.elibraryofcambodia.org



## សរសៃប្រសាទប្រែប្រួល ទុកចិត្តមិនបាន

ពេលខ្សែបេះដូងរត់ទៅរកខ្សែខួរក្បាល ដែលនៅក្រោមម្រាមកណ្តាល បញ្ជាក់ដល់មនុស្សដែលរំភើបខ្លាំង ប៉ុន្តែពេលខ្លះ ក្នុងការស្វែងរកក្តីស្រឡាញ់ក៏បែរជាផ្លាស់ប្តូរយកជាការមិនបានទៅវិញ។ មនុស្សបែបនេះជាមនុស្សមានសរសៃប្រសាទប្រែប្រួល។



## ចាស់មុនវ័យ

ខ្សែបេះដូងពីរស្របគ្នា ដោយខ្សែទីមួយវាបញ្ចប់ត្រឹមក្រោមម្រាមកណ្តាល បង្ហាញដល់មនុស្សដែលចាស់មុនវ័យ។ ទោះជាយ៉ាងណាក៏ដោយ ការវិវត្តបែបនេះអាចបង្កឲ្យកើតក្តីលំបាកបាន។ អ្វីដែលសំខាន់សម្រាប់មនុស្សបែបនេះ គឺគួរប្រយ័ត្នប្រយែងបញ្ហាផ្លូវភេទដែលអាចកើតមានឡើងក្នុងពេលនោះ។



www.elibraryofcambodia.org

## ធម្មជាតិពីរផ្នែក



ពេលខ្សែខួរក្បាលពីរស្របគ្នា ជាខ្សែត្រង់ឆ្ពោះទៅរកពកព្រហស្បតិ៍ក្រោមម្រាមចង្អុល វាជាសញ្ញានៃបុគ្គលិកលក្ខណៈផ្សេងគ្នា។ គេអាចជាមនុស្សគួរឲ្យស្រឡាញ់ចូលចិត្តធ្វើខ្លួនសប្បាយៗ ឬជាមនុស្សអាត្មានិយម និងពិបាករស់នៅជាមួយផង។ មនុស្សបែបនេះមានចំណង់ផ្លូវភេទខ្លាំង-ក្លា ហើយជួបនឹងការផ្លាស់ប្ដូរយ៉ាងច្រើនក្នុងជីវិតរបស់ពួកគេ។

## ក្ដីស្រឡាញ់ដ៏ស៊ីជម្រៅនិងពិតប្រាកដ



ខ្សែបេះដូងទេរចុះមករកពកអង្គារទាប បង្ហាញដល់ក្ដីស្រឡាញ់ដែលស៊ីជម្រៅនិងពិតប្រាកដ។ មនុស្សបែបនេះតស៊ូពុះពារនឹងក្ដីស្រឡាញ់ ដែលមានការប្រែប្រួលច្រើនក្នុងជីវិតរបស់ពួកគេ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ គឺអ្នកសិល្បៈនិងអ្នកនិពន្ធ ដែលមានអារម្មណ៍ទន់ភ្លន់ច្រើនតែមានខ្សែបេះដូងបែបនេះ។



www.elibraryofcambodia.org



## អាត្មានិយម

ខ្សែបេះដូងចុងបំផុតក្រោមពកសៅរ៍ បញ្ជាក់ដល់មនុស្សអាត្មានិយម។ ពួកគេត្រូវកាត់បន្ថយទស្សនៈបែបនេះ ដើម្បីធ្វើឲ្យជីវិតរស់នៅរបស់ខ្លួនកាន់តែមានភាពងាយស្រួលច្រើនឡើង។



## ត្រូវការទាំងអស់ឬមិនយកតែម្តង

ខ្សែបេះដូងដែលឆ្ពោះទៅត្រង់ចង្អែកម្រាមរវាងម្រាមចង្អុលនិងម្រាមកណ្តាល បង្ហាញដល់មនុស្សដែលយកចិត្តទុកដាក់ទៅលើក្តីស្រឡាញ់យ៉ាងខ្លាំង ហើយវែមទាំងមានអត្ថន័យទៀតផង។ លើសពីនេះទៀត បើគេមិនស្រេកឃ្លានតម្រូវការខ្ពស់ គេក៏មិនចង់បានអ្វី។



www.elibraryofcambodia.org

ស្រឡាញ់ខ្លាំង ប៉ុន្តែក៏
ប្រចណ្ឌខ្លាំងគួរឲ្យខ្លាចដែរ



ពេលខ្សែបេះដូងកាត់តាមបាតដៃត្រង់ដូចបន្ទាត់ បង្ហាញដល់ក្ដីស្រឡាញ់ដ៏ខ្លាំងក្លា ប៉ុន្តែក៏បង្ហាញដល់ការប្រចណ្ឌមួយ ដែលស្ថិតក្នុងកម្រិតដ៏គ្រោះថ្នាក់ដែរ។

ចំណង់ផ្លូវភេទខ្ពស់



ពេលខ្សែបេះដូងទាំងពីរនិងខ្សែខួរក្បាលមានលក្ខណៈតូចៗជាប់គ្នាមានលក្ខណៈអង្កាញ់ បញ្ជាក់ថា ជាមនុស្សដែលចូលចិត្តរឿងផ្លូវភេទច្រើន។ ពួកគេមិនពេញចិត្តដៃគូមួយទល់នឹងមួយទេ ហើយអាចផ្លាស់ប្ដូរដៃគូជាញឹកញាប់ ដើម្បីស្វែងរកបទពិសោធខាងផ្លូវភេទថ្មីៗ



www.elibraryofcambodia.org



## ស្រឡាញ់ដោយចេះទទួលខុសត្រូវ និងស្មោះត្រង់

ពេលខ្សែបេះដូងបែកចេញជាពីរទិស យ៉ាងច្បាស់ដូចនេះ បង្ហាញថាជាមនុស្ស ដែលស្មោះត្រង់ចំពោះស្នេហា។ ពេលណា ដែលពួកគេសម្រេចចិត្តចង់រស់នៅជាមួយ នឹងនរណាម្នាក់ ពួកគេនឹងទទួលខុសត្រូវ ហើយស្មោះត្រង់ ថែមទាំងគ្មានថ្ងៃបោះបង់ សម្ពន្ធភាពរបស់ខ្លួនឡើយ។

## មានបញ្ហាល្អក្នុងរឿងស្នេហា



ពេលមានសញ្ញាកូនកោះបីកើតលើ ខ្សែបេះដូង បង្ហាញពីការមានបញ្ហាដ៏ល្អក្នុង រឿងស្នេហា។ ពួកគេដឹងពីវិធីគិតនិងតម្រូវការ របស់ដៃគូខ្លួនជានិច្ច។



www.elibraryofcambodia.org

គូគ្រងដែលចេះបត់បែន



ខ្សែបេះដូងដែលមានលក្ខណៈជារលក បង្ហាញពីភាពបត់បែនក្នុងរឿងស្នេហា។ មនុស្សដែលមានខ្សែបេះដូងបែបនេះ នឹងផ្តល់ការសហការបានល្អ និងមានហេតុផល ថែមទាំងគ្មានថ្ងៃបណ្តោយឲ្យអារម្មណ៍មកលេបត្របាក់បានឡើយ។

ស្នេហាបែកបាក់



ខ្សែបេះដូងដែលដាច់ចេញពីគ្នាដូចដែលបានឃើញនេះ បង្ហាញដល់សេចក្តីស្រឡាញ់ខ្វះភាពល្អកល្អើន ទោះបីមានសញ្ញាគ្រោះថ្នាក់ក៏ដោយ ប៉ុន្តែបើពួកគេផ្លាស់ប្តូរស្ថានភាពនោះបាន នោះនឹងល្អប្រសើរ។ បទពិសោធដែលពួកគេបានឆ្លងកាត់ នឹងធ្វើឲ្យពួកគេកាន់តែរឹងមាំឡើង។



www.elibraryofcambodia.org



**ទេពកោសល្យបែបអ្នកការទូតនិង វោហារសាស្ត្រ**

ពេលមានខ្សែតូចៗពីរឬបីខ្សែកើតឡើង នៅគល់ខ្សែបេះដូង គឺបង្ហាញពីលក្ខណៈរបស់ មនុស្សដែលមានភាពប៉ិនប្រសប់បែបអ្នក ការទូត។



**សំណាងល្អក្នុងរឿងស្នេហា**

បើមានខ្សែតូចៗជាច្រើនឡើងនៅលើ ខ្សែបេះដូង បង្ហាញដល់សំណាងល្អក្នុងរឿង ស្នេហា។ សម្រាប់មនុស្សម្នាក់នេះ ស្នេហា ប្រៀបបានដូចជាគ្រែដែលក្រាលទៅដោយផ្កា កុលាប។



www.elibraryofcambodia.org



## សមត្ថភាពខាងសិល្បៈ

ខ្សែបេះដូងបែបនេះ បង្ហាញដល់មនុស្សដែលមានសិល្បៈ រំភើប និងទន់ភ្លន់។ ពួកគេនឹងទទួលបានជោគជ័យយ៉ាងច្រើន តាមរយៈការប្រើគំនិតច្នៃប្រឌិត ដូចជាការងារនិពន្ធឬគូររូបភាពជាដើម។

## ស្នេហាដែលគ្មានសេចក្តីសុខ

មនុស្សម្នាក់នេះនឹងទទួលបានសម្ពន្ធភាពស្នេហាដែលកំពុងតស៊ូដើម្បីឲ្យបានស្រស់បំព្រងបន្តទៀត។ ពួកគេនឹងមានអារម្មណ៍ថា ត្រូវគូគ្រងយល់ខុសនិងបោះបង់ចោល ដែលធ្វើឲ្យពួកគេគ្មានសេចក្តីសុខ។





www.elibraryofcambodia.org



### បញ្ឈប់ម្ភាថយដោយសារស្នេហាគ្មានសេចក្តីសុខ

ពេលខ្សែបេះដូងបែកចេញជាពីរទិសបែបនេះ គឺបង្ហាញដល់ស្នេហាដែលគ្មានសេចក្តីសុខ។ មនុស្សប្រភេទនេះបន្ថែមសេចក្តីឈឺចាប់និងសេចក្តីអស់សង្ឃឹម ប៉ុន្តែវាគ្រាន់តែកើតឡើងបណ្តោះអាសន្នប៉ុណ្ណោះ។ បើពួកគេចេះស្វែងរកផ្លូវចេញពីស្ថានភាពបែបនេះ នោះនឹងធ្វើឲ្យមានភាពប្រសើរឡើង។



### បែកផ្លូវគ្នាបណ្តោះអាសន្ន

សញ្ញាកូនកោះដែលស្ថិតនៅចុងខ្សែបេះដូង គឺចង្អុលបង្ហាញដល់ការបែកផ្លូវពីគូស្នេហ៍ក្នុងរយៈពេលខ្លី។ ជួនកាលអាចដោយសារពីការខ្វែងគំនិតគ្នាក៏ថាបាន។ ទោះជាយ៉ាងណាក៏ដោយ វាមានន័យថា ដៃគូរបស់អ្នកឃ្លាតទៅមួយរយៈ ដើម្បីទៅធ្វើការនៅកន្លែងឆ្ងាយៗ។



www.elibraryofcambodia.org

### ការបែកពីគ្នាជាស្ថាពរ



សញ្ញាកាកបាទដែលស្ថិតនៅចុងខ្សែ គឺបង្ហាញដល់ការបែកគ្នាជាស្ថាពរ។ នេះជាសញ្ញាបង្ហាញដ៏អាក្រក់បំផុត។

### ការបណ្ដោយខ្លួនឬមានសហាយ



ពេលចុងខ្សែបេះដូងតូចល្អិត ទាំងក្រោមទាំងលើ គឺបង្ហាញដល់ការបណ្ដោយខ្លួនយ៉ាងពិតប្រាកដ ឬសម្ពន្ធភាពមិនគង់វង្ស។ នេះជាលក្ខណៈរបស់មនុស្សដែលមានតម្រូវការខាងផ្លូវភេទខ្ពស់។



www.elibraryofcambodia.org

## ស្នេហាត្រីកោណ



ខ្សែទល់នឹងចន្លោះខ្សែជីវិតនិងខ្សែបេះដូង ហើយមានសញ្ញាផ្កាយត្រង់ចុងខ្សែ ជាសញ្ញាអវិជ្ជមាន។ វាជាលក្ខណៈរបស់មនុស្សដែលពាក់ព័ន្ធនឹងស្នេហាត្រីកោណ។ ស្ថានភាពបែបនេះធ្វើឲ្យកើតមានការប្រើកលល្បិចឬការប្រចណ្ឌរវាងភាគីដែលពាក់ព័ន្ធ ហើយដែលអាក្រក់បំផុត គឺសម្ពន្ធភាពស្នេហានឹងបញ្ចប់ដោយសោកនាដកម្ម តែទោះបីជាយ៉ាងណាក៏ដោយ ក៏នៅមានសំណាងល្អខ្លះដែរ ព្រោះខ្សែបែបនេះ មានតួនាទីបង្ហាញគ្រោះថ្នាក់ទុកជាមុន ពេលគឺ ភាគីទាំងបីអាចធ្វើអ្វីមួយទាក់ទងនឹងស្ថានភាពនេះ។

## សម្ពន្ធភាពស្នេហាដ៏លំបាកដែលទាក់ទងនឹងមនុស្សជាច្រើន



ពេលចុងខ្សែបេះដូងរត់ទៅរកម្រាមចង្អុល ប៉ុន្តែមានខ្សែមួយទៀត ដែលមានសញ្ញាកូនកោះត្រង់គល់ខ្សែរត់ទៅរកខ្សែខួរក្បាល នេះជាសញ្ញាអវិជ្ជមាន ដែលបង្ហាញដល់ស្នេហាត្រីកោណដែលមិនចប់ដោយសេចក្តីសុខ។ ខ្សែបន្ទាប់អាចនឹងកាត់តាមខ្សែខួរក្បាលឬខ្សែជីវិត ហើយបើវាកាត់កាន់តែវែង មនុស្សនោះក៏ទទួលការឈឺចាប់កាន់តែច្រើន។ ទោះជាយ៉ាងណាក៏ដោយ ក៏មានឱកាសអាចដោះស្រាយស្ថានភាពនេះបានដែរ។ មនុស្សដែលទាក់ទង ត្រូវជ្រើសរើសយកភាគីណាមួយ ជាជាងការចាត់ការទាំងពីរភាគីក្នុងពេលតែមួយ។



www.elibraryofcambodia.org

## សម្ពន្ធភាពដែលមានរយៈពេលខ្លី



សញ្ញាកូនកោះក្រោមខ្សែបេះដូងត្រង់ក្រោមម្រាមនាង ជាសញ្ញាមិនល្អ ដែលបង្ហាញដល់សម្ពន្ធភាពដែលគ្មានដំណើរការល្អនិងមិនយូរអង្វែង។ នេះច្រើនតែសំដៅដល់មនុស្សស្រីដែលជាប្រពន្ធលួចលាក់។

## មុខងារដែលត្រូវមើលងាយក្នុងសម្ព័ន្ធភាពស្នេហា



ពេលមានសញ្ញាបួនជ្រុងលើខ្សែបេះដូង គឺបង្ហាញដល់មនុស្សដែលមិនប្រកាន់ខ្ជាប់ក្នុងសម្ពន្ធភាពស្នេហា ហើយត្រូវធ្វើខ្លួនដូចជាតួកំប្លែងមួយរូប។



www.elibraryofcambodia.org

## ព្យាយាមនិងយកចិត្តចំពោះតួនាទី



ពេលមានខ្សែលេចឡើងនៅក្រោមខ្សែបេះដូង គឺបង្ហាញដល់ការយកចិត្តទុកដាក់ចំពោះតួនាទី ឧស្សាហ៍ព្យាយាម និងមានសមត្ថភាពដ៏អស្ចារ្យក្នុងការធ្វើការ។ មនុស្សបែបនេះហ៊ានលះបង់ខ្លួនឯងដើម្បីឡើងឲ្យដល់គោលដៅដ៏ខ្ពស់បំផុត។

## បេះដូងដែលទន់ខ្សោយនិងយ៉ាប់យ៉ឺន



ពេលខ្សែបេះដូងមានខ្សែតូចៗខុសពីធម្មតា (A) ទាំងក្រោមទាំងលើ ដូចជាចំណុចតូចៗ (B) កាត់ខ្សែបេះដូង គឺបង្ហាញដល់បេះដូងទន់ខ្សោយ និងមានដំណើរការមិនប្រក្រតី។ អ្វីដែលសំខាន់សម្រាប់មនុស្សពួកនេះ គឺត្រូវប្រយ័ត្នប្រយែងជាទីបំផុត។



www.elibraryofcambodia.org



# ខ្សែអាជីព

ខ្សែនេះបង្ហាញដល់ឱកាសក្នុងអាជីព។ បើខ្សែអាជីពវែងនិងច្បាស់ បង្ហាញថា អ្នកកំពុងតែមានអាជីពក្នុងផ្លូវវិជ្ជមាន ចំណែកខ្សែដែលប្រែប្រួល បង្ហាញដល់មនុស្សដែលសម្រេចចិត្តមិនច្បាស់លាស់ ហើយច្រើនតែផ្លាស់ប្តូរការងារនិងទិសដៅអាជីពជាប់ជានិច្ច។ ដូច្នេះចៅហ្វាយគ្រប់គ្នាគួរត្រួតពិនិត្យខ្សែនេះសិន មុននឹងទទួលបុគ្គលិកថ្មីឲ្យចូលធ្វើការ។ ខ្សែអាជីពច្រើនតែចាប់ផ្តើមពីចំណុចកណ្តាលបាតដៃ ហើយឆ្ពោះទៅត្រង់ពកក្រោមម្រាមចង្អុល ម្រាមកណ្តាល ម្រាមនាង និងម្រាមកូន។ ករណីទីមួយ អ្នកនឹងអាចស្វែងរកអំណាចបានច្រើន ករណីទីពីរ អ្នកនឹងទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ ករណីទីបី អ្នកនឹងមានកេរ្តិ៍ឈ្មោះក្នុងមជ្ឈដ្ឋានសិល្បៈ និងក្នុងករណីចុងក្រោយ អ្នកនឹងរីកចម្រើនរុងរឿងខាងផ្លូវសេដ្ឋកិច្ច។



www.elibraryofcambodia.org

## ជាបន្តទៅនេះគឺការវិភាគលក្ខណៈខ្សែអាជីពនិងអត្ថន័យរបស់វា




### ខ្សែផ្សេងៗដែលបែកចេញពីខ្សែអាជីព

ពេលមានខ្សែផ្សេងៗបែកចេញពីខ្សែអាជីព គឺជាសញ្ញាដ៏ល្អខ្លាំងណាស់ ដែលបង្ហាញឲ្យឃើញថា មនុស្សបែបនេះនឹងទទួលបានឱកាសដែលល្អច្រើនឡើង។ ខ្សែដែលឆ្ពោះទៅកាន់ចំណុចA គឺពួកគេមានមហិច្ឆតាខ្លាំងនិងទទួលបានជោគជ័យលើអ្វីៗគ្រប់យ៉ាង ហើយខ្សែខ្លីៗដែលឆ្ពោះទៅកាន់ចំណុចB មានន័យថា ពួកគេនឹងប្រមូលផ្ដុំកម្លាំងទាំងអស់ទៅរកទិសដៅដ៏ពិតប្រាកដមួយ ដើម្បីសម្រេចគោលដៅក្នុងជីវិត។ ខ្សែដែលឆ្ពោះទៅកាន់ចំណុចC ឬពកដែលនៅចន្លោះលីនិងស៊ីន គឺសំដៅដល់អាជីពដែលទទួលបានជោគជ័យ។ ខ្សែដែលឆ្ពោះទៅកាន់ពកពុធ C ជាលក្ខណៈនៃការបានកម្រៃនិងភាពជោគជ័យខាងសេដ្ឋកិច្ច។




### របួសជីវិតពីឧបទ្ទវហេតុដ៏អាក្រក់

សញ្ញាបួនជ្រុងលើខ្សែអាជីព (A) សំដៅដល់ការរបួសជីវិតពីឧបទ្ទវហេតុអាក្រក់ ដែលកើតឡើងក្នុងពេលអនាគតដ៏ខ្លី។ សញ្ញាបួនជ្រុងត្រង់គល់ខ្សែអាជីព (B) បង្ហាញដល់មនុស្សដែលអាចដោះស្រាយទំនាស់ក្នុងគ្រួសារឲ្យកើតមានប្រយោជន៍បាន។



www.elibraryofcambodia.org

## ឧប្បត្តិហេតុដែលប្រុងនឹងកើតឡើង



សញ្ញាកាកបាទត្រង់ចុងខ្សែអាជីព ជាសញ្ញាឧប្បត្តិហេតុដែលកំពុងនឹងកើតឡើង។ ដូច្នេះអ្នកដែលមានលក្ខណៈបែបនេះគួរមានការប្រយ័ត្នប្រយែង។

## ចាប់អារម្មណ៍ក្នុងរឿងធម្មជាតិ



ពេលមានខ្សែកាត់ទទឹងមកពីខ្សែបេះដូង ឬខ្សែខួរក្បាលមកកាត់ខ្សែអាជីព គឺបង្ហាញដល់ចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះរឿងធម្មជាតិ។ ភាគច្រើនមនុស្សបែបនេះមានអំណាចចិត្តពិសេសដូចជាមើលឃើញហេតុការណ៍នៅខាងមុខបាន។



www.elibraryofcambodia.org

## ជីវិតដ៏រឹងមាំ



ពេលខ្សែជីវិតខ្លីខ្លាំង តែខ្សែអាជីព កើតឡើងត្រង់កដៃដោយមានខ្សែបែកជំមួយ មានន័យថា ជីវិតនឹងបានបន្ថែមភាពរឹងមាំ ដោយខ្សែជួយសង្គ្រោះ។ ទោះជាយ៉ាងណាក៏ដោយ ចំណុចដែលខ្សែជីវិតនិងខ្សែបែកធំនេះជួបគ្នា អាចជាសញ្ញានៃការផ្លាស់ប្តូរដ៏ធំក្នុងជីវិតរបស់ពួកគេ។

## ការចាប់ផ្តើមថ្មីក្នុងជីវិត



ខ្សែអាជីពដែលលេចឡើងមកត្រង់កណ្តាលបាតដៃ បង្ហាញដល់ការចាប់ផ្តើមជាថ្មីនៅពេលមានអាយុប្រមាណ៤៥-៥៥ឆ្នាំ។ អាជីពដែលចាប់ផ្តើមថ្មីនឹងនាំមកនូវទំនួលខុសត្រូវដ៏ធំធេង។



www.elibraryofcambodia.org

## ខ្សែជោគជ័យដែលហាត់នឿយនិងពិបាក

ខ្សែអាជីពដែលលេចឡើងលើខ្សែខួរក្បាល បង្ហាញដល់ជីវិតដែលលំបាក។ មនុស្សបែបនេះនឹងត្រូវធ្វើការនិងក្រីក្រពេញមួយជីវិត។



## បានទទួលការពេញនិយមនិងកោតសរសើរ

ពេលខ្សែអាជីពចេញពីខ្សែបែកពីរ គឺបង្ហាញដល់ការពេញនិយម។ មនុស្សបែបនេះនឹងមានជីវិតរស់នៅស្រួល ដោយបានទទួលការជួយសង្គ្រោះ និងការយកចិត្តទុកដាក់យ៉ាងខ្លាំងពីសំណាក់គ្រួសារនិងមិត្តភ័ក្តិ។





www.elibraryofcambodia.org

## ឧស្សាហ៍ព្យាយាម



ពេលខ្សែអាជីពចេញពីចំណុចកណ្តាលនៃខ្សែជីវិត គឺបង្ហាញដល់សមត្ថភាពនិងការលះបង់ខ្លួនយ៉ាងខ្លាំង។ នេះជាសញ្ញានៃការធ្វើការងារច្រើន និងការសម្រេចគោលដៅ។

## ភាពស្មុកស្មាញ



ពេលខ្សែអាជីពចេញពីទីតាំងកដៃហើយរត់ទៅត្រង់ដូចដែលបានឃើញ គឺបង្ហាញដល់ភាពស្មុកស្មាញ ហើយបានទទួលការឧបត្ថម្ភយ៉ាងច្រើន។ មនុស្សបែបនេះ ជាមនុស្សដើរដើរបានឆ្ងាយ ហើយថែមទាំងជួយជ្រុមជ្រែងពីអ្នកនៅក្បែរខ្លួនគេទៀតផង។



www.elibraryofcambodia.org

## ផ្លាស់ប្ដូរយ៉ាងខ្លាំងក្លា

ខ្សែតូចៗ ជាច្រើនខ្សែឡើងពីខ្សែជីវិត បង្ហាញដល់ការផ្លាស់ប្ដូរគំនិតជាញឹកញាប់ ខ្សែដែលតាំងឡើងជាសញ្ញាវិជ្ជមាន ខ្សែចុះក្រោមជាសញ្ញាអវិជ្ជមាន មនុស្សបែបនេះពិបាកនឹងភ្ជាប់ខ្លួនទៅនឹងទិសដៅដែលពិតប្រាកដ និងមិនដឹងថា ត្រូវធ្វើអ្វីឲ្យពិតប្រាកដពីជីវិតរបស់ពួកគេ ហើយពួកគេអាចនឹងមានការផ្លាស់ប្ដូរធំក្នុងជីវិតលើផ្នែកអាជីព ទីកន្លែង ឬគូគ្រង។



## ឥទ្ធិពលដ៏រឹងមាំរបស់គ្រួសារ

ពេលដើមខ្សែអាជីពនិងដើមខ្សែជីវិតជាប់គ្នា បង្ហាញដល់ឥទ្ធិពលដ៏ធំធេងរបស់គ្រួសារ ជាញឹកញាប់មនុស្សបែបនេះនឹងដើរតាមគន្លងរបស់ឪពុកម្ដាយ ហើយពេលខ្លះអាចគ្រប់គ្រងអាជីពដូចជាឪពុកម្ដាយពួកគេទៀតផង។





www.elibraryofcambodia.org

## ស្ថានភាពមិនល្អទាំងនៅកន្លែងធ្វើការនិងនៅផ្ទះ




ចំណុចដែលលេចឡើងមកលើខ្សែអាជីព (A) បង្ហាញដល់សេចក្តីលំបាកតោកយ៉ាកនៅកន្លែងធ្វើការ។ ខ្សែដែលឡើងត្រង់ចំណុច B និងចុងបំផុតមួយលើខ្សែអាជីព បញ្ជាក់ថាមនុស្សដែលស្និទ្ធស្នាលជាមួយនឹងបុគ្គលប្រភេទនេះអាចពាក់ព័ន្ធនឹងរឿងរ៉ាវ។ សញ្ញាផ្កាយ C ដែលលេចឡើងលើខ្សែអាជីព ជាសញ្ញាដែលកំពុងបោកប្រាស់ពួកគេ។

## សម្ពន្ធភាពស្នេហាដែលត្រូវបញ្ចប់ភ្លាមៗ



ពេលមានខ្សែមួយបែកចេញពីពកចន្ទមកកាត់ខ្សែអាជីព គឺបង្ហាញដល់សម្ពន្ធភាពស្នេហាដែលត្រូវបញ្ចប់ភ្លាមៗ ថែមទាំងប្រាប់ថា គូគ្រងរបស់មនុស្សពួកនេះកំពុងឃ្លាតឆ្ងាយដោយគ្មានប្រាប់ទុកជាមុន។



www.elibraryofcambodia.org

### បាត់បង់អាជីព

ខ្សែអាជីពដែលចុងផុតឡើងមកត្រង់កណ្ដាលបាតដៃ បង្ហាញដល់អាជីពមិនមានដំណើរការ វាថែមទាំងមានន័យបានទៀតថា មនុស្សបែបនេះបណ្ដោយឲ្យជីវិតរសាត់អណ្ដែតទៅតាមយថាកម្ម ដោយប្រាសចាកគោលដៅផ្សេងៗបានទៀតផង។



### អាជីពមិនមានដំណើរការ

ខ្សែអាជីពចុងផុតឡើងមកត្រង់ចំណុចទល់នឹងខ្សែខួរក្បាល បង្ហាញដល់ភាពមិនមានដំណើរការក្នុងពេលមានអាយុ៣០ឆ្នាំ ដែលកើតពីរឿងអាស្រូវដែលនឹកស្មានមិនដល់។ ដូច្នេះទើបគួរប្រយ័ត្នប្រយែងក្នុងវ័យនោះ។





www.elibraryofcambodia.org

## ការពាក់ព័ន្ធទៅនឹងរឿងស្នេហារបស់អ្នកដទៃដែលមិនមែនជារបស់អ្នក



ពេលខ្សែអាជីពមានចុងផុតឡើងមកត្រង់ចំណុចប្រសព្វនឹងខ្សែបេះដូង គឺបង្ហាញដល់ការចូលទៅពាក់ព័ន្ធរឿងស្នេហារបស់អ្នកដទៃដោយមិនសមគួរ។ នេះមានន័យថាមនុស្សបែបនេះអាចត្រូវអ្នកដទៃបោកប្រាស់ឲ្យធ្វើសកម្មភាពមួយចំនួនដែលមិនត្រឹមត្រូវ គឺពួកគេពិបាកគេចចេញពីស្ថានភាពនេះបានណាស់។ ដូច្នេះទើបគួរប្រយ័ត្នប្រយែងទុកជាមុន។

## សំណាងល្អនិងការរីកចម្រើន



ពេលខ្សែអាជីពឡើងដល់ចុងផុតក្រោមម្រាមចង្អុល គឺបង្ហាញដល់ការប្រុងនឹងដោះស្រាយបញ្ហាបាន មិនយូរប៉ុន្មានក៏នឹងជឿជាក់លើខ្លួនឯង។ នេះជាសញ្ញាដ៏ល្អ ជាពិសេសនៅពេលវាលេចឡើងលើបាតដៃរបស់នារី ដែលបញ្ជាក់ថា ពួកនាងមានសម្ពន្ធភាពជាមួយនឹងមនុស្សជុំវិញខ្លួន។



www.elibraryofcambodia.org

## អាជីពថ្មី



ខ្សែអាជីពដែលកើតចេញពីខ្សែខួរក្បាលបែបនេះ ជាសញ្ញាមានឱកាសដ៏ធំផេងខាងផ្នែកអាជីព។ វាថែមទាំងជាមូលដ្ឋាននៃភាពឈានមុខនិងជាឱកាសដែលរកប្រាក់បានទៀតផង។

## សមត្ថភាពខាងសិល្បៈ



ខ្សែអាជីពដែលកើតចេញពីពកចន្ទ ជាសញ្ញានៃសមត្ថភាពផ្នែកសិល្បៈ។ ខ្សែក្រៅបំផុត (A) បង្ហាញដល់សមត្ថភាពសិល្បៈច្នៃប្រឌិត។ ខ្សែទីពីរ (B) បញ្ជាក់ដល់ការបើកចំហ និងយកចិត្តទុកដាក់លើការងារ ហើយឃ្លាតឆ្ងាយពីការឈ្លក់វង្វេងក្នុងរឿងផ្លូវភេទទៀតផង។ ខ្សែទីបី (C) បង្ហាញដល់អាជីពដែលទាក់ទងនឹងរឿងភេទផ្ទុយគ្នា មានន័យថាមនុស្សបែបនេះនឹងពូកែខាងរចនាម៉ូតសម្លៀកបំពាក់។ ចំពោះបុរសដែលមានសញ្ញាបែបនេះនឹងមានឈ្មោះបោះសំឡេងខាងផ្នែករចនាម៉ូតសម្រាប់នារី រីឯនារីដែលមានសញ្ញាបែបនេះ នឹងពូកែខាងរចនាម៉ូតសម្លៀកបំពាក់សម្រាប់បុរស។



www.elibraryofcambodia.org



### មហិច្ឆតាហួសហេតុហួតដល់ខុសពីការពិត

ខ្សែអាជីពដែលឡើងត្រង់ទៅដល់គល់នៃម្រាមកណ្ដាល គឺបង្ហាញដល់មហិច្ឆតាខុសទិសដៅ សំណាងមិនល្អដែលមនុស្សបែបនេះគ្មានសមត្ថភាពសម្រេចគោលដៅលើអ្វីដែលពួកគេជឿថា អាចធ្វើបាន។

### រឹងរូស

ខ្សែអាជីពដែលវែង ត្រង់ និងច្បាស់ ជាសញ្ញាដ៏ល្អ។ ផ្ទុយទៅវិញ វាអាចនឹងមានន័យថា មនុស្សបែបនេះងប់ងុលនឹងខ្លួនឯង ហើយជាមនុស្សរឹងរូសច្រើន។ ដូច្នេះទើបពួកគេគួរតែរួមដៃជាមួយនឹងអ្នកដទៃឲ្យកាន់តែច្រើនឡើង ហើយគួរតែមានភាពប៉ិនប្រសប់ផ្នែកការទូតឲ្យកាន់តែច្រើនឡើង។





www.elibraryofcambodia.org



## ខ្សែស្នេហានិងអាពាហ៍ពិពាហ៍

ខ្សែនេះតូចៗ ដែលនៅក្រោមម្រាមកូន។ បើខ្សែនេះទន់និងខ្លី គឺបង្ហាញដល់រឿងរ៉ូមែនទិករយៈពេលដ៏ខ្លីនិងប្រាសចាកភាពសំខាន់។ បើខ្សែនេះវែងនិងមើលឃើញច្បាស់ គឺបង្ហាញដល់ការមានស្នេហាយ៉ាងពិតប្រាកដ រហូតអាចឈានដល់ការរៀបអាពាហ៍ពិពាហ៍ទៀតផង។ ខ្សែដែលមិនដាច់និងគ្មានខ្សែតូចគងគ្នា គឺបង្ហាញដល់សម្ពន្ធភាពដ៏ល្អឬរលូន។ ខ្សែដែលត្រូវបែកចេញដោយខ្សែតូចៗជាច្រើន គឺបង្ហាញដល់ជីវិតអាពាហ៍ពិពាហ៍មិនល្អ និងចាំបាច់ត្រូវចាប់អារម្មណ៍រវាងខ្សែបេះដូងនិងខ្សែម្រាមកូនដៃ បង្ហាញដល់កំលុងពេលកើតមានស្នេហា។ ពេលខ្សែស្នេហានិងការរៀបអាពាហ៍ពិពាហ៍កើតឡើងនៅចន្លោះនោះ បង្ហាញថា អ្នកនឹងជួបនរណាម្នាក់នៅពេលណាមួយ ហើយខ្សែស្នេហានិងអាពាហ៍ពិពាហ៍កាន់តែខិតជិតខ្សែបេះដូងច្រើន អ្នកក៏មានស្នេហាលឿនខ្លាំងឡើង។



www.elibraryofcambodia.org

បន្តទៅនេះការវិភាគសញ្ញាខ្សែស្នេហាអាពាហ៍ពិពាហ៍និងអត្ថន័យរបស់វា

## សម្ពន្ធភាពច្រើន



ពេលមានខ្សែតូចៗជាច្រើនស្ថិតនៅក្រោមម្រាមកូន គឺបង្ហាញដល់ការទទួលបានការពេញនិយមយ៉ាងខ្លាំង និងចូលចិត្តបណ្តោយខ្លួន។ ជាញឹកញាប់ មនុស្សបែបនេះមានអារម្មណ៍ភ័យអរដែលមានសម្ពន្ធភាពជាមួយនឹងអ្នកដទៃ តែវាក៏ដូចជាធ្ងន់ធ្ងរនិងគួរឲ្យខកចិត្តមិនតិចដែរ។

## សម្ពន្ធភាពដ៏អាប់អួ



ពេលខ្សែអាពាហ៍ពិពាហ៍ចុះទៅរកខ្សែបេះដូង គឺបញ្ជាក់ដល់សម្ពន្ធភាពដ៏អាប់អួ បើភាគីទាំងពីចង់ឲ្យសម្ពន្ធភាពមានដំណើរការបន្តទៀត ពួកគេត្រូវកែតម្រូវការឈ្វេងយល់រវាងគ្នានិងគ្នាឲ្យបានច្រើនឡើង ហើយយកចិត្តទុកដាក់ទៅលើតម្រូវការនិងអារម្មណ៍គ្នាទៅវិញទៅមក។



www.elibraryofcambodia.org

## សម្ពន្ធភាពដែលបានទទួលការកែតម្រូវឲ្យប្រសើរឡើង

១

ពេលខ្សែអាពាហ៍ពិពាហ៍បែកចេញពីគ្នាដូចដែលបានឃើញ គឺបង្ហាញដល់សម្ពន្ធភាពដ៏អាប់អួដែលបានទទួលការកែតម្រូវឲ្យប្រសើរឡើងតាមពេលវេលាដែលកន្លងផុតទៅ ហើយអ្វីផ្សេងៗត្រឡប់មកដូចដើមនិងពោរពេញទៅដោយក្តីស្រឡាញ់ម្តងទៀត។ ភាគីទាំងពីរកំពុងធ្វើល្អបំផុតដើម្បីឲ្យដំណើរការសម្ពន្ធភាពរបស់ពួកគេទទួលបានជោគជ័យ។



## ភាពមិនចុះសម្រុងគ្នា

១

ពេលខ្សែអាពាហ៍ពិពាហ៍ត្រូវកាត់ដោយខ្សែដែលមានទំហំប៉ុនម្ទុល គឺជាសញ្ញានៃសម្ពន្ធភាពដ៏អាប់អួ គ្មានភាគីណាយល់លើភាគីណាឡើយ ហើយថែមទាំងខ្វះសម្ពន្ធភាពនិងអារម្មណ៍ដ៏ស៊ីជម្រៅចំពោះគ្នាទៀតផង។





www.elibraryofcambodia.org



## សម្ពន្ធភាពដែលបែកចេញជាពីរផ្លូវ

ពេលខ្សែស្នេហានិងអាពាហ៍ពិពាហ៍ បង្ហាញដល់ការបែកចេញជាពីរទិសដៅយ៉ាងច្បាស់បែបនេះ គឺបង្ហាញថា សម្ពន្ធភាពនឹងជួបបញ្ហាក្នុងពេលដ៏ខ្លី។ ភាគីដែលពាក់ព័ន្ធមិនមានចំណាប់អារម្មណ៍និងគោលដៅជីវិតតែមួយាងទៀតឡើយ ហើយបើខ្សែងបែកចេញពីគ្នាកាន់តែធំ ភាពខុសប្លែករវាងភាគីទាំងពីរក៏កាន់តែច្រើនដែរ។ ជាញឹកញាប់ដែលសម្ពន្ធភាពវិលត់ទៅ ក៏ដោយសារភាគីទាំងពីរមិនរក្សាឲ្យល្អ ទោះជាយ៉ាងណាក៏ដោយ សម្ពន្ធភាពនេះមានឱកាសអាចសម្រុះសម្រួលគ្នាបាន បើភាគីទាំងពីរយកចិត្តទុកដាក់រួមគ្នាដោះស្រាយ។



www.elibraryofcambodia.org



## ខ្សែនៃភាពជោគជ័យ

ខ្សែនៃភាពជោគជ័យបង្ហាញដល់កេរ្តិ៍ឈ្មោះនិងការទទួលស្គាល់។ វានៅក្រោមម្រាមនាងលើពកស៊ីន ( ពកអាទិត្យ ) ហើយបើខ្សែនេះវែងនិងមានសញ្ញាល្អ កេរ្តិ៍ឈ្មោះនិងការទទួលស្គាល់ក៏ទៅតាមនោះដែរ ទោះជាអ្នកជ្រើសរើសធ្វើអ្វីក៏ដោយ អ្នកនឹងទទួលបានជោគជ័យយ៉ាងងាយ។ ប្រភេទមនុស្សដែលប្រើគំនិតច្នៃប្រឌិត ដូចជាអ្នកសម្តែង អ្នកសិល្បៈ និងអ្នកនិពន្ធ នឹងមានសញ្ញាបែបនេះនៅក្នុងដៃគេ។



www.elibraryofcambodia.org

បន្តទៅនេះគឺការវិភាគសញ្ញារបស់ខ្សែនៃភាពជោគជ័យនិងអត្ថន័យរបស់វា

## បានទទួលការកោតសរសើរនិងការរាប់អានពីមនុស្សស្និទ្ធស្នាល



ពេលខ្សែនៃភាពជោគជ័យកើតឡើងលើខ្សែបេះដូង ជាសញ្ញានៃជោគជ័យរបស់អ្នក។ នេះជានិមិត្តសញ្ញាវិជ្ជមាន មានន័យថា សំណាងនិងសេចក្ដីសុខនឹងនៅជាមួយនឹងអ្នក។

## ជីវិតដែលគ្រប់គ្រាន់



នេះជាសញ្ញាខ្សែសំណាងល្អ ដែលច្រើនតែលេចឡើងមករួមជាមួយនឹងខ្សែអាជីព។ ក្នុងករណីនេះ មនុស្សបែបនេះនឹងសម្រេចដល់គោលបំណងខ្ពស់បំផុតដែលពួកគេចង់ធ្វើ។ ខ្សែនេះអាចរឹងមាំ ឬជាខ្សែដ៏ទន់ខ្សោយនិងខ្លីជាងនេះក៏ថាបាន ហើយបើខ្សែនេះកាន់តែវែងកាន់តែល្អ ហើយអាចស្វែងរកកេរ្តិ៍ឈ្មោះនិងលាភសំណាងទៀតផង។



www.elibraryofcambodia.org

## មហិច្ឆតាហួសហេតុ



បើមានខ្សែមួយកាត់ខ្សែភាពជោគជ័យ ត្រូវគិតល្អិតល្អន់មុននឹងធ្វើគម្រោងថ្មីបាន។ សញ្ញាដូចនេះបង្ហាញថា មនុស្សបែបនេះវាយតម្លៃសមត្ថភាពខ្លួនឯងខ្ពស់ពេក ដែលធ្វើឲ្យមានសត្រូវច្រើនជាងមិត្ត ទើបពួកគេគួរប្រយ័ត្នប្រយែង ជាពិសេសដើម្បីគេចវេះរឿងអាស្រូវ។

## ធ្វើអ្វីច្រើនក្នុងពេលតែមួយនឹងឃ្លាតឆ្ងាយពីភាពជោគជ័យ



ពេលមានខ្សែតូចៗជាច្រើននៅក្រោមម្រាមនាង ជាសញ្ញារបស់មនុស្សដែលធ្វើអ្វីច្រើនយ៉ាងក្នុងពេលតែមួយ។ អ្វីដែលសំខាន់សម្រាប់ពួកគេ គឺការគិតឲ្យគ្រប់ជ្រុងជ្រោយមុននឹងធ្វើអ្វីថ្មីៗ។ ការព្យាយាមធ្វើការងារឬមុខជំនញបច្ចុប្បន្ន ជារឿងល្អជាងសម្រាប់ពួកគេ។



www.elibraryofcambodia.org



# ខ្សែលុយ

ខ្សែតូចៗជាច្រើនដែលលេចឡើងក្រោមម្រាមកូនដៃ គឺខ្សែលុយ បង្ហាញថា អ្នកនឹងទទួលបានជោគជ័យលើការងាររបស់អ្នក បើវាលេចឡើង អ្នកប៉ះត្រូវអ្វី ក៏ក្លាយទៅជាមាសជាប្រាក់ទាំងអស់។



www.elibraryofcambodia.org



## សញ្ញាលើបាតដៃ

សញ្ញាផ្កាយជាសញ្ញាសំណាងល្អ មិនថាវារះនៅកន្លែងណាលើបាតដៃឡើយ។ ជាញឹកញាប់វាបន្ថែមភាពរឹងមាំទៅលើសញ្ញាផ្សេងៗទៀត។ ទោះជាយ៉ាងណាក៏ដោយ មុននឹងអ្នកបន្ថែមអត្ថន័យវិជ្ជមានទៅលើបាតដៃ អ្នកគួរវិភាគវាជាមុនសិន។



www.elibraryofcambodia.org

## សញ្ញាផ្កាយ



ផ្កាយមួយនៅលើពកសុក ជាសញ្ញានៃការឈ្នះក្តីស្រឡាញ់។ បណ្តាមនុស្សទាំងឡាយដែលមានគេចូលចិត្ត ច្រើនតែមានសញ្ញានេះនៅលើបាតដៃ។

## ផ្កាយមួយនៅលើពកអង្គារ



នេះបង្ហាញដល់កិត្តិយសខាងទាហាន ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ច្រើនតែមានសញ្ញាបែបនេះ។



www.elibraryofcambodia.org

## ផ្កាយមួយនៅលើពកព្រហស្បតិ៍

នេះជាសញ្ញាដែលផ្តល់គុណសម្បត្តិផ្សេងៗ បើដៃល្អ វានឹងមានសញ្ញានៃភាពជាអ្នកដឹកនាំ។



## ផ្កាយមួយនៅលើពកអាទិត្យ

បង្ហាញដល់ភាពឈ្លាសវៃនិងបានការទទួលស្គាល់យ៉ាងច្រើន។





www.elibraryofcambodia.org

### ផ្កាយមួយនៅលើពកពុធ



បញ្ជាក់ដល់សមត្ថភាពនិងភាពជោគជ័យខាងផ្នែកវិទ្យាសាស្ត្រ នៅគ្រាចុងក្រោយនៃជីវិត។

### ផ្កាយមួយនៅលើពកអង្គារខ្ពស់



បង្ហាញដល់កិត្តិយសខាងទាហាននៅគ្រាចុងក្រោយនៃជីវិត។ ជាញឹកញាប់ ពួកមេទ័ពទាំងឡាយច្រើនតែមានសញ្ញានេះ។



www.elibraryofcambodia.org

## ផ្កាយមួយនៅលើពកចន្ទ

ជាសញ្ញានៃការស្រមើស្រមៃមិនគួរឲ្យជឿ។ ជាញឹកញាប់ វាបង្ហាញដល់គម្លាតរវាងអ្នកដែលពោរពេញដោយការស្រមើស្រមៃនិងមនុស្សឆ្លាត។





www.elibraryofcambodia.org

## សញ្ញាបីជ្រុង



សញ្ញាបីជ្រុងជាសញ្ញាដែលផ្តល់លាភឲ្យអ្នកជានិច្ច។ ទោះវាជាសញ្ញាដែលមើលច្បាស់ ហើយមិនមានលេចចេញនូវខ្សែអ្វីនោះទេ។

## សញ្ញាបីជ្រុងមួយនៅលើពកសុក



បង្ហាញដល់ឥទ្ធិពលក្នុងផ្នែកក្តីស្រឡាញ់និងរឿងគេទ។



www.elibraryofcambodia.org

## សញ្ញាបីជ្រុងមួយនៅលើពកព្រហស្បតិ៍

ជាសញ្ញារបស់អ្នករៀបចំអង្គការដ៏ធំធេង និងជាអ្នកដឹកនាំដែលទទួលបានជោគជ័យយ៉ាងខ្ពស់។



## សញ្ញាបីជ្រុងមួយនៅលើពកអាទិត្យ

បង្ហាញដល់មនុស្សមានសិល្បៈ ឬមនុស្សមានគំនិតច្នៃប្រឌិតហើយជឿជាក់លើខ្លួនឯង ឬជាតន្ត្រីករដ៏ជំនាញ។





www.elibraryofcambodia.org



## សញ្ញាបីជ្រុងនៅលើពកពុធ

បង្ហាញដល់ភាពជំនាញក្នុងរង្វង់អ្នកកីឡាដ៏ល្បី អ្នកសេដ្ឋកិច្ចដ៏កំពូល។

## សញ្ញាបីជ្រុងមួយនៅលើពកអង្គារខ្ពស់



ជាសញ្ញានៃភាពអង់អាចក្លាហាន រួមទាំងមានចំណេះដឹងដ៏ទូលំទូលាយផ្នែកទាហាននិងការត្រួតពិនិត្យ។



www.elibraryofcambodia.org

## សញ្ញាបីជ្រុងមួយនៅលើពកចន្ទ



បង្ហាញដល់ការស្រមើស្រមៃកម្រិតខ្ពស់។ វាជាសញ្ញាវិជ្ជមានសម្រាប់អ្នកនិពន្ធ។

## ខ្សែដេកឬខ្សែឈរជាច្រើននៅលើពកផ្សេងៗ



ខ្សែឈរទាំងអស់ធ្វើឲ្យដៃរឹងមាំ។ ចំណែកខ្សែដេកទាំងអស់ធ្វើឲ្យដៃខ្សោយ។ ខ្សែឈរនៅលើខ្សែជីវិត ខ្សែអាជីព និងខ្សែអាទិត្យ សុទ្ធតែបន្ថែមខ្សែទាំងនេះ។ ខ្សែដេកទាំងអស់ដែលឆ្លងកាត់ខ្សែទាំងនេះបង្ហាញដល់ឧបសគ្គ។



www.elibraryofcambodia.org



ខ្សែឈរជាច្រើននៅលើពកព្រហស្បតិ៍

បង្ហាញដល់ភាពជោគជ័យ របស់មេដឹកនាំខាងនយោបាយ ខាងទាហាន ឬសាសនា។



ខ្សែឈរជាច្រើននៅលើពកអាទិត្យ

ច្រើនតែបន្ថែមភាពរឹងមាំដល់ខ្សែអាទិត្យ ហើយបង្ហាញដល់ភាពជោគជ័យខាងសិល្បៈច្នៃប្រឌិតនៅគ្រាចុងក្រោយនៃជីវិត។



www.elibraryofcambodia.org

## ខ្សែឈរជាច្រើននៅលើពកពុធ



ច្រើនតែបន្ថែមភាពរឹងមាំដល់ខ្សែលុយ បង្ហាញដល់ភាពជោគជ័យខាងជំនួញ។

## ខ្សែឈរជាច្រើននៅលើពកចន្ទ



នេះច្រើនតែច្រឡំនឹងខ្សែបញ្ញា និងខ្សែសុខភាព ប៉ុន្តែខ្សែនេះបង្ហាញដល់ការធ្វើដំណើរ។



www.elibraryofcambodia.org

## ខ្សែឈរជាច្រើននៅលើពកអង្គារទាប អង្គារខ្ពស់ និងពកវរុណ



ពកអង្គារទាបនិងពកអង្គារខ្ពស់ មានសម្ពន្ធនឹងរឿងរ៉ាវក្នុងគ្រួសារ ចំណែកពកវរុណតភ្ជាប់នឹងទ្រព្យសម្បត្តិ រួមទាំងទាក់ទងនឹងឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទ។ ខ្សែឈរជាច្រើនជាសញ្ញាវិជ្ជមាន វាបន្ថែមភាពរឹងមាំដល់សមត្ថភាពក្នុងការប្រើឧបករណ៍អេឡិចត្រូនិច។ ជាមួយគ្នានោះ ក៏បង្ហាញថា មនុស្សបែបនេះចូលចិត្តផ្តល់ជំនួយសង្គ្រោះដល់អ្នកដទៃទៀតផង។



## ខ្សែដេកជាច្រើននៅលើពកសុក្រ

បើខ្សែទាំងនេះកាត់ខ្សែជីវិត វានឹងដាស់អារម្មណ៍ទុកជាមុនចំពោះហេតុការណ៍ក្នុងផ្លូវអវិជ្ជមានដែលបម្រុងនឹងកើតឡើង។



www.elibraryofcambodia.org



## ខ្សែដេកជាច្រើននៅលើពកអង្គារទាប

ខ្សែដេកជាច្រើនដែលលេចឡើងលើពកអង្គារទាបតភ្ជាប់នឹងរឿងរ៉ាវក្នុងគ្រួសារ ឬបងប្អូន។ បើខ្សែទាំងនេះល្អ មិនដាច់ និងមិនកាត់តាមខ្សែគោល (ដូចជា ខ្សែជីវិត ខ្សែខួរក្បាល ឬខ្សែអាជីព) ទេ វានឹងបង្ហាញដល់ខ្សែ ដែលមានអត្ថន័យក្នុងផ្លូវវិជ្ជមាន ហើយមានឥទ្ធិពលដ៏ត្រឹមត្រូវ។ ផ្ទុយទៅវិញ បើវាកាត់ខ្សែទាំងនេះឬវាជាខ្សែដាច់ នឹងជាសញ្ញារបស់បងប្អូនដែលបង្កឲ្យកើតមានបញ្ហា។

## ខ្សែដេកជាច្រើននៅលើពកព្រហស្បតិ៍



នេះបង្ហាញដល់ការមិនព្រមតាមដានការដឹកនាំរបស់អ្នកដទៃឬ មិនយកចិត្តទុកដាក់លើពាក្យទូន្មានរបស់សាសនា។



www.elibraryofcambodia.org

## ខ្សែដេកជាច្រើននៅលើពកអាទិត្យ



ជាសញ្ញាអវិជ្ជមាននៃកម្លាំង នៅត្រង់កណ្តាលនៃគំនិតច្នៃប្រឌិត។

## ខ្សែដេកជាច្រើននៅលើពកពុធ



បង្ហាញដល់ឥទ្ធិពលអវិជ្ជមាន សម្រាប់កីឡាករ អ្នកជំនួញ ឬ អ្នកណាក៏ដោយដែលចង់ទទួលបានជោគជ័យ គឺវាពិបាកណាស់។



www.elibraryofcambodia.org

## ខ្សែដេកជាច្រើននៅលើពកចន្ទ



បង្ហាញដល់ភាពជោគជ័យក្នុងការធ្វើដំណើរ បើវាមិនមែនជាខ្សែដាច់។

## សញ្ញាកាកបាទនៅលើពកព្រហស្បតិ៍ និងខ្សែក្រវាត់អង្គារ



ពកព្រហស្បតិ៍ជាសញ្ញានៃអំណាច ឯសញ្ញាកាកបាទច្រើនតែតភ្ជាប់នឹងគុណសម្បត្តិលើសពីធម្មតា។ ការលេចសញ្ញាកាកបាទលើពកនេះ ជាសញ្ញាពិតប្រាកដនៃការមានអំណាចចិត្តពិសេស។



www.elibraryofcambodia.org



## សញ្ញាបួនជ្រុងនៅលើបាតដៃ

ជាសញ្ញានៃការគ្រប់គ្រងនិង ការពាររឿងលំបាកគ្រប់ប្រភេទ។



## ខ្សែគោលទាំងបួននៅលើបាតដៃមានលក្ខណៈប្រហាក់ប្រហែលតួអក្សរ M

ខ្សែដែលសំខាន់បំផុតលើបាតដៃ គឺខ្សែជីវិត ខ្សែខួរក្បាល ខ្សែបេះដូង ខ្សែអាពាហ៍ពិពាហ៍ និងខ្សែអាជីព។ ពេលខ្សែទាំងនេះភ្ជាប់គ្នានឹងក្លាយតួអក្សរM ជាសញ្ញាដ៏ល្អបំផុត ដោយសារវាបង្ហាញដល់ការចាប់ផ្តើមនិងភាពរឹងមាំរបស់ខ្សែទាំងនេះ។ បើខ្សែកាន់តែវែង នោះកាន់តែល្អ។



www.elibraryofcambodia.org



ម្រាមដៃនិងម្រាមមេមានប្រភេទផ្សេងៗគ្នា

### ម្រាមមេ

ម្រាមមេបង្ហាញដល់គោលបំណងនិងវិធីសម្រេចចិត្ត។ បើម្រាមមេដៃរឹងមាំ ជាសញ្ញានៃសុខភាពល្អ កិរិយាមារយាទល្អ និងសមត្ថភាពជាអ្នកដឹកនាំ។ បុរសដែលមានម្រាមមេរឹងមាំច្រើនតែជាអ្នកស្មោះត្រង់។

### ម្រាមចង្អុល

ម្រាមបង្ហាញដល់អំណាចនិងមហិច្ឆតា។ បើម្រាមចង្អុលក្រាស់និងរឹងមាំ គឺបង្ហាញដល់មនុស្សដែលមានគោលបំណងខ្ពស់និងពេញចិត្តស្វែងរកអំណាច។ អ្នកនយោបាយនិងអ្នកដឹកនាំពាណិជ្ជកម្មដ៏ល្អ ច្រើនតែមានចង្អុលដៃបែបនេះ។ ពួកគេច្រើនតែទទួលបានជោគជ័យលើអ្វីផ្សេងៗដែលពាក់ព័ន្ធនឹងពួកគេនិងអ្នកដទៃ។



www.elibraryofcambodia.org

### ម្រាមកណ្តាល

ម្រាមកណ្តាលបង្ហាញដល់ការដឹងខុសដឹងត្រូវនិងសីលធម៌។ បើម្រាមកណ្តាលក្រាស់រឹងមាំនិងត្រង់ ជាសញ្ញានៃទំនួលខុសត្រូវ ប៉ុន្តែបើម្រាមកណ្តាលវែងជ្រុល ជាសញ្ញានៃការត្រិះរិះច្រើននិងការចូលចិត្តធ្វើអ្វីផ្សេងៗតាមវិធីរបស់ខ្លួនឯង។

### ម្រាមនាង

ម្រាមនាងបង្ហាញដល់ផ្នែកសិល្បៈរបស់មនុស្សយើង។ បើម្រាមនាងរឹងមាំ ក្រាស់ និងវែង គឺបង្ហាញដល់មនុស្សដែលមកពីគ្រួសារដ៏ស្តុកស្តម្ភ។ ផ្ទុយទៅវិញ បើម្រាមនាងវែងនិងក្រាស់ គឺបង្ហាញដល់ការចូលចិត្តលេងល្បែងស៊ីសង។

### ម្រាមកូន

ម្រាមកូនបង្ហាញដល់វិធីដែលមនុស្សយើងចូលចិត្តសង្គមជុំវិញខ្លួន។ បើម្រាមក្រាស់និងរឹងមាំ គឺបង្ហាញដល់អ្នកការទូតដែលពូកែសន្ទនា។ ម្រាមកូនដែលល្អគួរវែងដល់គន្លាក់ម្រាមនាងទីពីរ។ បើម្រាមកូនខ្លីជាងនេះ បង្ហាញដល់ភាពខ្មាសអៀនក្នុងសង្គម។ មនុស្សមួយចំនួនដែលមានម្រាមកូនខ្លី អាចនឹងមានបញ្ហាទាក់ទងនឹងការមានគភ៌បាន។

## ចុងម្រាមមានប្រភេទផ្សេងៗគ្នា

ទ្រង់ទ្រាយនៃចុងម្រាមដែលបានជួបជាញឹកញាប់មានបួនប្រភេទ ដូចជា ស្រួច មូល ទាល និងបួនជ្រុង។ ប្រភេទនីមួយៗបង្ហាញដល់ឧបនិស្ស័យរហូតដល់ជោគជតាដែលខុសប្លែកពីគ្នា។



www.elibraryofcambodia.org

## ចុងម្រាមដៃស្រួច

មនុស្សប្រភេទនេះជាអ្នកសិល្បៈ រ៉ូមែនទិក និងទន់ភ្លន់ អាចមានភាពជាអ្នកការទូតនៅក្នុងខ្លួន ហើយចូលចិត្តសេពគប់ជាមួយនឹងមិត្តភ័ក្តិថ្មីៗ។ ពួកគេថែមទាំងជាមនុស្សមានឧត្តមគតិខ្ពស់ទៀតផង ដោយមិនសូវឲ្យតម្លៃទៅលើរឿងមាសប្រាក់។ ភាពស្មុកស្មាញមិនមែនជារឿងសំខាន់សម្រាប់ពួកគេទេ។

## ចុងម្រាមដៃមូល

មនុស្សប្រភេទនេះមានសតិបញ្ញា ប៉ុន្តែច្រើនតែខ្វះភាពអត់ធ្មត់ក្នុងការធ្វើអ្វីមួយឲ្យសមរម្យ។ អ្នកសិល្បៈជាច្រើន ច្រើនតែមានចុងម្រាមដៃបែបនេះ ពួកគេត្រូវយល់ពីភាពអត់ធ្មត់ និងធ្វើម្តងមួយរឿងដើម្បីទទួលបានជោគជ័យ។

## ចុងម្រាមដៃបួនជ្រុង

មនុស្សប្រភេទនេះមានការយល់ដឹងច្រើន រហ័សរហួនឬប្រយ័ត្នប្រយែង និងច្នៃប្រឌិត ថែមទាំងមានសមត្ថភាពខ្លាំងក្នុងការរៀបចំទៀតផង មានន័យថាពួកគេអាចទៅបានឆ្ងាយលើវិថីការងារផ្សេងៗ ឬមានភាពស្មុកស្មាញនិងមានកេរ្តិ៍ឈ្មោះក្នុងថ្ងៃណាមួយជាមិនខាន។

## ចុងម្រាមដៃទាល

មនុស្សប្រភេទនេះស្រឡាញ់សេរីភាពណាស់ ចូលចិត្តធ្វើដំណើរ និងចូលចិត្តចំណាយពេលនៅក្រៅផ្ទះ។ ពួកគេជាអ្នកបដិវត្តនិងមានមហិច្ឆតាដែលនឹងអាចសម្រេចដល់គោលដៅក្នុងជីវិត។



www.elibraryofcambodia.org




## ចង្វៃករវាងម្រាមដៃ



### ចង្វៃករវាងម្រាមចង្អុលនិងម្រាមកណ្ដាល

បង្ហាញដល់មនុស្សដែលមិនចូលចិត្តនៅក្រោមការគ្រប់គ្រងរបស់អ្នកដទៃ។ ផ្ទុយទៅវិញ ពួកគេឆ្លាតណាស់។ ដូច្នេះទើបពួកគេអាចមានបាននិងមានកេរ្តិ៍ឈ្មោះដោយមិនពិបាកព្យាយាមច្រើន។



www.elibraryofcambodia.org

### ចង្វៃកម្រាមកណ្ដាលនិងម្រាមនាង



បង្ហាញដល់មនុស្សដែលចូលចិត្តសេរីភាពឬមានសេរីភាព។ ផ្ទុយទៅវិញ ពួកគេត្រូវធ្វើការច្រើនដើម្បីវិថីជីវិតបែបនេះ ហើយអាចបណ្ដែតបណ្ដោយជីវិតពីមួយថ្ងៃទៅមួយថ្ងៃដោយប្រាសចាកពីគោលដៅ។

### ចង្វៃកម្រាមនាងនិងកូនដៃ



បង្ហាញដល់មនុស្សដែលមានគំនិតសម្រាប់ខ្លួនឯង ហើយចូលចិត្តធ្វើអ្វីផ្សេងៗ ដោយខ្លួនឯង ថែមទាំងបង្ហាញដល់ភាពជាអ្នកសិល្បៈនិងការមានគំនិតច្នៃប្រឌិតទៀតផង ដែលអាចដឹងពីតម្រូវការផ្ទាល់ខ្លួន។ ពួកគេអាចមានបាននិងមានឈ្មោះបោះសំឡេងដោយមិនបាច់ត្រូវព្យាយាមច្រើនប៉ុន្មានទេ។



www.elibraryofcambodia.org

## ចង្វែកគ្រប់ចន្លោះម្រាមដៃ



ជាសញ្ញានៃការមិនសន្សំសំចៃ ហើយរស់នៅមិនតាមទំនៀមទម្លាប់។ មនុស្សប្រភេទនេះមើលពិភពលោកក្នុងទស្សនៈល្អ តែពេលខ្លះក៏ជួបបញ្ហាខាងសេដ្ឋកិច្ចដែរ ដោយសារមិនជំនាញរឿងប្រាក់កាស។

## គ្មានចង្វែកម្រាមដៃ



បង្ហាញដល់ការប្រយ័ត្នប្រយែង និងភាពជាអ្នកអភិរក្សនិយម។ ពួកគេនឹងត្រិះរិះលើអ្វីៗគ្រប់យ៉ាងទុកជាមុន ហើយមិនព្រមបណ្តោយឲ្យអ្វីបាត់បង់ទៅទទេរៗទេ។ ពួកគេនឹងទៅបានឆ្ងាយក្នុងការស្វែងរកកេរ្តិ៍ឈ្មោះនិងលាភសំណាង។



www.elibraryofcambodia.org

**កែងរវាងម្រាមមេដៃនិងម្រាមចង្អុល
ចង្អៃកធំជាង៩០ដឺក្រេ**



បង្ហាញដល់មនុស្សក្លាហាននិងមានចិត្តទូលាយ។ ជាញឹកញាប់ វាជាសញ្ញារបស់អ្នកជំនួញដែលត្រូវចំណាយប្រាក់កាសមុននឹងប្រមូលមកវិញនៅពេលក្រោយ។

**កែងរវាងម្រាមមេដៃនិងម្រាមចង្អុល
ចង្អៃកតិចជាង៦០ដឺក្រេ**



បង្ហាញដល់ការប្រយ័ត្នប្រយែងរឿងប្រាក់កាស ប៉ុន្តែមនុស្សប្រភេទនេះពូកែរកប្រាក់ហើយអាចបាត់បង់មិត្តភ័ក្តិព្រោះគិតពីប្រយោជន៍ផ្ទាល់ខ្លួន។



www.elibraryofcambodia.org

## ខ្មៅម្រាមដៃ
### គ្រប់ម្រាមមានខ្មៅ



ខ្មៅដៃ បង្ហាញដល់មនុស្សល្អិតល្អន់ និងភាពជាអ្នកគ្រប់គ្រងដ៏ល្អ។ ពេលគ្រប់ម្រាមសុទ្ធតែមានខ្មៅ បញ្ជាក់ដល់ភាពជឿជាក់លើខ្លួនឯង ស្រឡាញ់សេរីភាព និងរឹងរូសខ្លាំង។ គុណសម្បត្តិទាំងអស់នេះ រមែងមានឥទ្ធិពលចំពោះជោគជតារបស់ពួកគេ។ ដូច្នេះអ្វីដែលសំខាន់សម្រាប់ពួកគេ គឺការគិតដល់សញ្ញានេះ ហើយពេលខ្លះ ពួកគេចាំបាច់ត្រូវមានភាពឆ្លៀវឆ្លា និងមានការប៉ិនប្រសប់ជាអ្នកការទូតច្រើនឡើង។

### មានតែម្រាមមេដៃប៉ុណ្ណោះដែលមានខ្មៅ



នេះជាសញ្ញាដ៏ល្អ ដែលបង្ហាញដល់ចរិតសុភាពទន់ភ្លន់ ភាពជាអ្នកការទូត និងមានសមត្ថភាពច្រើនផ្នែក។ វាជាសញ្ញាបញ្ជាក់ពីគោលបំណងខ្ពស់និងមានថាមពលពិសេស។ តែផ្ទុយទៅវិញ ពួកគេច្រើនតែខ្វះភាពអត់ធ្មត់។



www.elibraryofcambodia.org

## មានតែម្រាមចង្អុលប៉ុណ្ណោះដែលមានខ្មៅ



មនុស្សប្រភេទនេះមានមុខមាត់នៅក្នុងសង្គមណាស់តែចូលចិត្តឆ្លៀតឱកាស និងតែងផ្លាស់ប្តូរចិត្តនៅពាក់កណ្តាលទី។ ទង្វើអវិជ្ជមាននេះ អាចនាំក្តីលំបាកដល់ពួកគេ បើពួកគេមិនព្រមផ្លាស់ប្តូរទស្សនៈ និងវិធីនេះទេ។

## មានតែម្រាមកណ្តាលប៉ុណ្ណោះដែលមានខ្មៅ



បង្ហាញដល់ការមានគោលដៅដ៏ខ្ពស់ក្នុងជីវិត ប៉ុន្តែគោលដៅនោះអាចនឹងសម្រេចបានយ៉ាងលំបាក។ មនុស្សប្រភេទនេះត្រូវស្វែងយល់ពីគោលដៅឲ្យសមស្របទៅតាមការពិត ហើយព្រមទាំងព្យាយាមគ្រប់ពេលវេលា នឹងធ្វើឲ្យពួកគេអាចទៅបានឆ្ងាយឬអាចទៅដល់គោលដៅបាន។



www.elibraryofcambodia.org

## មានតែម្រាមនាងប៉ុណ្ណោះដែលមានខ្មៅ



មនុស្សប្រភេទនេះនឹងទទួលបានជោគជ័យយ៉ាងច្រើននៅអំឡុងពេលដំបូងក្នុងជីវិត។ ពួកគេជាអ្នកដឹកនាំដ៏ល្អ ហើយបើចេះអត់ធ្មត់ ក៏នឹងទទួលបានជោគជ័យយ៉ាងច្រើនថែមទៀត។

## មានតែម្រាមកូនប៉ុណ្ណោះដែលមានខ្មៅ



បង្ហាញដល់សុខភាពទន់ខ្សោយ មានមេត្រីនិងមានសមត្ថភាពជាច្រើនផ្នែក។ អ្នកដទៃនឹងជួយឈឺឆ្អាលមនុស្សប្រភេទនេះបានយ៉ាងងាយ ហើយច្រើនតែពេញចិត្តជួយសង្គ្រោះពួកគេ។ ពួកគេនឹងឈានទៅមុខបានយ៉ាងឆ្ងាយក្នុងអាជីពប៉ុន្តែដំបូងបំផុត ពួកគេត្រូវទុកចិត្តលើអ្នកដទៃជាមុនសិន។



www.elibraryofcambodia.org

## មានតែស្រាមមេដៃនិងស្រាមចង្អុលប៉ុណ្ណោះដែលមានខ្មៅ



បង្ហាញដល់ភាពអត់ធ្មត់និងភាពក្លៀវក្លាជាខ្លាំង។ មនុស្សប្រភេទនេះមានចិត្តទន់ និងច្រើនតែទទួលយកបញ្ហាអ្នកដទៃមកដាក់ខ្លួនដោយមិនគិតទុកជាមុន ទើបពួកគេត្រូវស្វែងយល់សិន មុននឹងជឿមនុស្សគ្រប់គ្នាដែលគេបានជួប។

## មានតែស្រាមមេដៃនិងស្រាមកណ្តាលប៉ុណ្ណោះដែលមានខ្មៅ

ជាសញ្ញាដែលបញ្ជាក់ពីការនៅមិនស្ងៀម បើមនុស្សប្រភេទនេះចូលចិត្តធ្វើការច្រើន ពួកគេនឹងទទួលបានជោគជ័យ ហើយច្រើនតែមានគេទទួលស្គាល់យ៉ាងទូលំទូលាយ។





www.elibraryofcambodia.org

## មានតែម្រាមមេដៃនិងម្រាមនាងប៉ុណ្ណោះ ដែលមានខ្ចៅ



មនុស្សប្រភេទនេះត្រូវធ្វើកាច្រើន ទើបទទួលបានជោគជ័យ។ អ្វីដែលសំខាន់ គឺពួកគេត្រូវគិតដល់ការពិតត្រង់ប្រការនេះ ហើយចាប់ផ្ដើមតាំងពីយុវវ័យ។ ពេលពួកគេមានអាយុច្រើនឡើង ពួកគេមានឱកាសច្រើនដែលនឹងបានទទួលតំណែងខ្ពស់ស្ដុកស្ដម្ភ រហូតដល់មានកេរ្តិ៍ឈ្មោះ។

## មានតែម្រាមមេដៃនិងម្រាមកូនប៉ុណ្ណោះដែលមានខ្ចៅ



បង្ហាញដល់មនុស្សពូកែរោហារ ទើបគួរជ្រើសរើសការងារផ្នែកទំនាក់ទំនង។ ពួកគេអាចទៅរួចយ៉ាងពិតប្រាកដនូវអ្វីដែលពួកគេជ្រើសរើស ពួកគេចូលចិត្តជំនួញដ៏កំពូល ហើយមានជំនាញផ្នែកទំនាក់ទំនង ឬការងារទីផ្សារ។



www.elibraryofcambodia.org

## មានតែម្រាមចង្អុលនិងម្រាមកណ្តាល ប៉ុណ្ណោះដែលមានខ្មៅ



បង្ហាញដលភាពត្រង់ទៅត្រង់មក ហើយមិនចូលចិត្តពាក្យបញ្ឆិតបញ្ឆៀង។ មនុស្សប្រភេទនេះនឹងមានអំណាចនិងជាអ្នកដឹកនាំក្នុងមជ្ឈដ្ឋានមួយចំនួនយ៉ាងពិតប្រាកដ ដោយសារម្រាមចង្អុលតំណាងឲ្យអំណាចឬជាអ្នកដឹកនាំ ចំណែកម្រាមកណ្តាលក៏តំណាងឲ្យភាពត្រឹមត្រូវ ចូលចិត្តយុត្តិធម៌។ ដូច្នេះទើបពួកគេប្រើអំណាចយ៉ាងមានតុល្យភាព។

## មានតែម្រាមចង្អុលនិងម្រាមនាង ប៉ុណ្ណោះដែលមានខ្មៅ



ជាសញ្ញាដែលបង្ហាញដល់ភាពរឹងរូសខ្លាំង គោលបំណងខ្ពស់ និងការដឹងពីតម្រូវការជីវិត។ ដោយគុណសម្បត្តិទាំងនេះ ទើបពួកគេច្រើនតែទទួលជោគជ័យ។



www.elibraryofcambodia.org

### មានតែម្រាមចង្អុលនិងម្រាមកូនប៉ុណ្ណោះ ដែលមានខ្ចៅ



ជាសញ្ញាដែលបញ្ជាក់ដល់ការរិះគិតនិងការដោះស្រាយចំពោះអ្វីផ្សេងៗបានយ៉ាងល្អតាំងពីវ័យដំបូងក្នុងជីវិត។ បើមនុស្សប្រភេទនេះធ្វើពួកគេនឹងចម្រើនរុងរឿង ព្រមទាំងបានទទួលផលតបស្នងនៅវ័យចុងក្រោយ។

### មានតែម្រាមកណ្ដាលនិងម្រាមនាងប៉ុណ្ណោះដែលមានខ្ចៅ



បង្ហាញដល់ការដឹងខុសដឹងត្រូវចូលចិត្តយុត្តិធម៌ និងភាពជាអ្នកសិល្បៈ។ ដោយសារម្រាមកណ្ដាលតំណាងឲ្យការដឹងខុសដឹងត្រូវ និងម្រាមនាងតំណាងឲ្យសមត្ថភាពខាងសិល្បៈទើបមនុស្សប្រភេទនេះស្វែងរកភាពជោគជ័យលើផ្នែកសិល្បៈ។ អ្នកសិល្បៈជាច្រើនដែលមានសមត្ថភាពនិងមានកេរ្តិ៍ឈ្មោះតាំងពីវ័យដំបូងនៃជីវិតនឹងមានខ្ចៅបែបនេះ ដែលជាសញ្ញានៃភាពជោគជ័យដ៏ធំធេងផ្នែកសិល្បៈ។



www.elibraryofcambodia.org

## មានតែម្រាមកណ្ដាលនិងម្រាមកូន ប៉ុណ្ណោះដែលមានខ្មៅ



បង្ហាញដល់ការផ្លាស់ប្ដូរយ៉ាងធំធេង និងមានភាពមិនគង់វង្សក្នុងជីវិត។ ពេលខ្លះ មនុស្សប្រភេទនេះនៅចំណុចខ្ពស់បំផុត ពេលខ្លះក៏នៅចំណុចទាបបំផុត។ បើពួកគេដឹងពីវិធីធ្វើនិងចេះឆ្មក់ឱកាស ពួកគេនឹងអាចទៅបានឆ្ងាយ។

## មានតែម្រាមនាងនិងម្រាមកូន ប៉ុណ្ណោះដែលមានខ្មៅ



បង្ហាញដល់មនុស្សដែលងាយនឹងខូចអារម្មណ៍ និងមានឧបនិស្ស័យទន់ខ្សោយ។ ពួកគេអាចធ្វើការដែលត្រូវប្រើជំនាញក្នុងទំនាក់ទំនងបានល្អ។ ផ្ទុយទៅវិញ ពួកគេយល់ពីការតាំងចិត្តរបស់អ្នកដទៃនិងពូកែប្រយ័ត្ន បើពួកគេដោះស្រាយគុណសម្បត្តិលើផ្នែកអវិជ្ជមាននេះបាន ក៏នឹងទទួលបានជោគជ័យក្នុងជីវិត។



www.elibraryofcambodia.org

## ឈ្នាងមានគ្រប់ម្រាម



ឈ្នាងច្រើនតែបង្ហាញដល់ភាពជាអ្នកសិល្បៈនិងភាពទន់ភ្លន់។ ជាមនុស្សដែលចេះទទួលខុសត្រូវច្រើន ហើយមានជំនាញក្នុងផ្លូវប្រតិបត្តិដ៏ល្អច្រើន។ ផ្ទុយទៅវិញ ពួកគេមិនសូវលេចធ្លោក្នុងសង្គមទេ។ ដូច្នេះទើបអាចកើតមានបញ្ហាជាមួយនឹងអ្នកដែលមានចំណែកពាក់ព័ន្ធខាងមុខជំនួញនិងក្ដីស្រឡាញ់នានា។

## មានតែម្រាមមេដៃប៉ុណ្ណោះដែលមានឈ្នាង



បង្ហាញដល់ការមិនចាប់អារម្មណ៍រឿងអំណាចនិងកេរ្តិ៍ឈ្មោះ។ មនុស្សប្រភេទនេះនឹងធ្វើអ្វីដែលខ្លួនពេញចិត្តប៉ុណ្ណោះ។ នេះជាសញ្ញានៃការនៅស្ងៀមដោយមិនសូវប្រឈមចំពោះគ្រោះភ័យ។ គុណសម្បត្តិដែលល្អជាងលក្ខណៈបែបនេះ គឺពួកគេមានមេត្រីចិត្តចូលចិត្តជួយអ្នកដទៃ ព្រមទាំងជាអ្នកស្វែងរកសេរីភាព។ ពេញមួយជីវិតរបស់ពួកគេ នឹងបានជួបមិត្តភ័ក្តិជាច្រើន ហើយគ្មានថ្ងៃកណ្ដោចកណ្ដែងឡើយ។



www.elibraryofcambodia.org

**មានតែម្រាមចង្អុលប៉ុណ្ណោះ**
**ដែលមានឈ្នាង**



បង្ហាញដល់ទំនួលខុសត្រូវ សុភាពរាបសា និងការលះបង់ខ្លួន ធ្វើឲ្យមនុស្សប្រភេទនេះមិនស័ក្តិសមនឹងចរចាខាងមុខជំនួញ ដូច្នេះទើបពួកគេគួរតែទទួលបានជោគជ័យក្នុងមជ្ឈដ្ឋានដែលទាក់ទងនឹងការសិក្សាឬសាសនាច្រើនជាង។

**មានតែម្រាមកណ្តាលប៉ុណ្ណោះ**
**ដែលមានឈ្នាង**



បង្ហាញដល់ភាពក្លាហាន ភាពឧស្សាហ៍ព្យាយាម និងការចូលចិត្តធ្វើការច្រើន។ មនុស្សប្រភេទនេះនឹងអាចទៅបានឆ្ងាយ ហើយមនុស្សម្នានឹងផ្តល់ការគាំទ្រារាល់គំនិតផ្សេងៗរបស់ពួកគេជានិច្ច។ ផ្ទុយទៅវិញ ពួកគេអាចជាមនុស្សមានគំនុំ និងមិនព្រមអភ័យទោសងាយៗឡើយ។ បើពួកគេតាំងចិត្តកែតម្រូវទស្សនៈអវិជ្ជមាននេះ ជីវិតចុងក្រោយរបស់ពួកគេនឹងស្រស់បំព្រងច្រើនឡើង។



www.elibraryofcambodia.org



**មានតែម្រាមនាងប៉ុណ្ណោះដែលមានឈ្នាង**

បង្ហាញដល់សុខភាពទន់ភ្លន់ និងភាពជាអ្នកការទូត។មនុស្សប្រភេទនេះនឹងឈានមុខក្នុងអាជីពនានាដែលពួកគេជ្រើសរើស ថែមទាំងបានទទួលការគាំទ្រពីមិត្តរួមការងារផង។ ចន្លោះពេលវ័យចុងក្រោយនៃជីវិត ពួកគេនឹងចម្រើនរុងរឿងគ្រប់ផ្នែក។



**មានតែម្រាមកូនប៉ុណ្ណោះដែលមានឈ្នាង**

នេះមិនមែនជាសញ្ញាដែលបង្ហាញពីភាពជាអ្នកជំនួញដ៏ល្អយ៉ាងពិតប្រាកដនោះទេ។ មនុស្សប្រភេទនេះចូលចិត្តចាយវាយប្រាក់កាសដោយប្រុងប្រយ័ត្ន ព្រមទាំងសន្សំសំចៃប្រាក់កាសណាស់។ គុណសម្បត្តិក្នុងផ្លូវវិជ្ជមានគឺ បើខ្សែអាជីពនិងខ្សែប្រាក់កាសល្អ ពួកគេក៏អាចបានអ្វីៗគ្រប់យ៉ាងតាមដែលត្រូវការ។ នេះថែមទាំងជាសញ្ញាដែលបង្ហាញដល់ភាពជាមនុស្សល្អយ៉ាងខ្លាំងទៀតផង។ ពួកគេពេញចិត្តចែករំលែកភាពស្មុកស្មាញដល់មិត្តភក្តិនិងសាច់ញាតិ។



www.elibraryofcambodia.org

## មានតែម្រាមមេដៃនិងម្រាមចង្អុល ប៉ុណ្ណោះដែលមានឈ្នាង



នេះបង្ហាញដល់ការធ្វើការច្រើន ប៉ុន្តែសម្រេចចិត្តមិនដាច់ខាតនិងខ្វះភាពអត់ធ្មត់។ វាថែមទាំងជាសញ្ញាបង្ហាញដល់ភាពទន់ខ្សោយម្យ៉ាង គឺពួកគេអាចដឹងថាអ្នកដទៃឆ្មក់ឱកាសពីពួកគេ ដែលអាចជារឿងភេទឬអាចជាផលមកពីគ្រឿងស្រវឹង។ ផ្ទុយទៅវិញ បើពួកគេអាចតតាំងនឹងការឈ្លក់វង្វេងនេះបាន ចុងក្រោយបំផុតពួកគេនឹងអាចទទួលបានជោគជ័យ។

## មានតែម្រាមមេដៃនិងម្រាមកណ្តាល ប៉ុណ្ណោះដែលមានឈ្នាង



បង្ហាញឲ្យឃើញដល់ការចាប់អារម្មណ៍តែខ្លួនឯងប៉ុណ្ណោះ។ មនុស្សប្រភេទនេះអាចមានបេះដូងល្អ និងយកចិត្តទុកដាក់លើអ្នកដទៃ ប៉ុន្តែជាញឹកញាប់ ពួកគេចូលចិត្តនៅម្នាក់ឯងច្រើនជាង ហើយចូលចិត្តធ្វើអ្វីផ្សេងៗដោយឯករាជ្យ ដោយមិនសុំការអនុញ្ញាតពីនរណាឡើយ។ ពួកគេមិនចូលចិត្តរស់នៅក្រោមសម្ពាធអ្នកដទៃទេ និងស្រឡាញ់សេរីភាពខ្លាំង។



www.elibraryofcambodia.org

## មានតែម្រាមមេដៃនិងម្រាមនាងប៉ុណ្ណោះ ដែលមានឈ្នាង



នេះជាសញ្ញារបស់មនុស្សអ្នកមានតែចូលចិត្តដាក់ខ្លួនធ្វើការជានិច្ច។ ទស្សនៈដូចនេះធ្វើឲ្យពួកគេឈានទៅមុខបានយ៉ាងល្អ ហើយកេរ្តិ៍ឈ្មោះនិងភាពស្តុកស្តម្ភនៅក្បែរដៃរបស់ពួកគេជានិច្ច។

## មានតែម្រាមមេដៃនិងម្រាមកូនប៉ុណ្ណោះដែលមានឈ្នាង



ជាសញ្ញាបង្ហាញដល់ការដឹងខុសត្រូវ។ មនុស្សប្រភេទនេះមានការផ្ចិតផ្ចង់និងស៊ូទ្រាំខ្លាំង ដែលធ្វើឲ្យមានសត្រូវច្រើនជាងមិត្ត។



www.elibraryofcambodia.org

## មានតែម្រាមចង្អុលនិងម្រាមកណ្ដាល ប៉ុណ្ណោះដែលមានឈ្នាង



បង្ហាញដល់ភាពទន់ភ្លន់និងពេញចិត្តជួយអ្នកដទៃ។ មនុស្សប្រភេទនេះជាមនុស្សដែលគួរឲ្យគោរពរាប់អានហើយអាចសាងកេរ្តិ៍ឈ្មោះបានដោយខ្លួនឯង។ ទោះជាជីវិតក្នុងវ័យដំបូងមិនងាយស្រួលសម្រាប់ពួកគេក៏ដោយ ប៉ុន្តែចុងក្រោយនៃជីវិតក៏អាចមានដំណើរការទៅបានយ៉ាងល្អដែរ។

## មានតែម្រាមចង្អុលដៃនិងម្រាមនាង ប៉ុណ្ណោះដែលមានឈ្នាង



បង្ហាញដល់ការមិនចាប់អារម្មណ៍លើភាពជាអ្នកដឹកនាំ។ មនុស្សប្រភេទនេះឈានទៅរឿយៗក្នុងសំណើរជីវិតតាមចង្វាក់របស់ខ្លួនឯងនិងដោយវិធីរបស់ខ្លួនឯង។ ពួកគេជាបុគ្គលដែលស្វែងយល់យ៉ាងច្បាស់ផ្នែកសិល្បៈ ប៉ុន្តែមិនបានប្រើសមត្ថភាពរបស់ខ្លួនធ្វើអ្វីប៉ុន្មានទេ។



www.elibraryofcambodia.org



**មានតែម្រាមចង្អុលនិងម្រាមកូនប៉ុណ្ណោះ ដែលមានឈ្នាង**

នេះបង្ហាញដល់អ្នកដឹកនាំ ដែលមានភាពអត់ធ្មត់ ចូលចិត្តជួយ សង្គ្រោះអ្នកដទៃ និងជាមនុស្សចិត្ត ទូលាយ។ ពួកគេថែមទាំងជាអ្នក ប្រតិបត្តិ និងអាចធ្វើការទាក់ទងនឹង គ្រឿងយន្តគ្រឿងចក្របានគ្រប់យ៉ាង។



**មានតែម្រាមកណ្ដាលនិងម្រាមនាង ប៉ុណ្ណោះដែលមានឈ្នាង**

បង្ហាញដល់ការមានគោល បំណងខ្ពស់ ប៉ុន្តែអាចខ្វះបទពិសោធ ដែលនឹងសម្រេចចិត្តបានយ៉ាងត្រឹមត្រូវ ទាក់ទងនឹងរឿងរ៉ាវផ្សេងៗ។ សញ្ញា បែបនេះថែមទាំងបានបង្ហាញដល់ការ មិនចាប់អារម្មណ៍ទៅលើរឿងប្រាក់ កាសទៀតផង។ ផ្ទុយទៅវិញ បើពួកគេ ធ្វើការធ្ងន់និងមានភាពអត់ធ្មត់ អ្វីផ្សេងៗ ក៏អាចមានដំណើរការទៅបានល្អ។



www.elibraryofcambodia.org

**មានតែម្រាមកណ្ដាលនិងម្រាមកូន
ប៉ុណ្ណោះដែលមានឈ្នាង**



ជាសញ្ញាបង្ហាញដល់ការដាក់ផែនការសម្រាប់អនាគត។ មនុស្សប្រភេទនេះស្ទាត់ជំនាញទប់ទល់នឹងការដាក់ទុនដែលមានការប្រថុយប្រថាន។ ពួកគេអាចគិតដល់ជីវិតចុងក្រោយ ដែលចម្រើនរុងរឿងនិងមានសេចក្ដីសុខ។

**មានតែម្រាមនាងនិងម្រាមកូន
ប៉ុណ្ណោះដែលមានឈ្នាង**



បង្ហាញដល់មនុស្សដែលមិនចំណាយពេលវេលាច្រើនក្នុងការអភិវឌ្ឍសមត្ថភាពខាងសិល្បៈរបស់ខ្លួន។ ពួកគេច្រើនតែមានគំនិតខ្ពស់ តែគ្មានថ្ងៃផ្លាស់ប្ដូរវាជាគម្រោងដ៏ពិតប្រាកដទេ។ ដូច្នេះអ្វីដែលសំខាន់សម្រាប់ពួកគេ គឺហ្វឹកហាត់តាំងពីវ័យដំបូងនៃជីវិត ដើម្បីធ្វើអ្វីផ្សេងៗយ៉ាងហ្មត់ចត់។ ជាការពិត ចំណាប់អារម្មណ៍ផ្នែកការងារសិល្បៈនឹងបានទទួលការគាំទ្រពីវ័យដំបូងក្នុងជីវិតរហូតដល់ជោគជ័យ។



www.elibraryofcambodia.org



## គន្លាក់ម្រាមដៃ

### គន្លាក់ម្រាមដៃផ្សេងៗ

គន្លាក់ម្រាមដៃគឺជាឆ្អឹងរបស់ម្រាមដៃ។ ម្រាមដៃទាំងប្រាំមានគន្លាក់ម្រាម ១៤។ នោះគឺ ម្រាមមេដៃពីរ ហើយក្រៅពីម្រាមនីមួយៗមានបីគន្លាក់ទៀត។



### ថ្នាំងម្រាមដៃវែង

នេះបង្ហាញដល់ភាពហ្មត់ចត់ និង ពូកតែតែដលៃជាសញ្ញានៃសតិបញ្ញាដ៏ល្អ។



www.elibraryofcambodia.org

## ថ្នាំងម្រាមដៃខ្លី



នេះបង្ហាញដល់ការមិនប៉ិនប្រសប់និងធ្វេសប្រហែស។ ទោះបីមនុស្សប្រភេទនេះមិនមែនជាមនុស្សល្ងង់ក៏ដោយ ប៉ុន្តែច្រើនតែគិតមិនគ្រប់ជ្រុងជ្រោយ។

## មានខ្សែទឹងខ្លីៗជាច្រើននៅលើតន្លាក់គ្រប់ម្រាម



បើមានខ្សែទឹងតូចជាច្រើននៅលើតន្លាក់គ្រប់ម្រាម នឹងជាសញ្ញាដ៏អាក្រក់បំផុត។ អ្នកដែលមានសញ្ញាបែបនេះ គួរបានទទួលការពិនិត្យមើលពីពេទ្យឲ្យទាន់ពេល។



www.elibraryofcambodia.org



**មានខ្សែទទឹងខ្លីៗរាងជារលកនៅលើ គន្លាក់គ្រប់ម្រាម**

បង្ហាញដល់សំណាងអាក្រក់ឬ មានបញ្ហាដែលនឹងកើតឡើង។ មនុស្ស ជំពូកនេះគួរប្រយ័ត្នប្រយែងឲ្យបាន ច្រើន។



**ខ្សែឈរខ្លីៗជាច្រើននៅលើគន្លាក់ ម្រាមគ្រប់ម្រាម**

នេះជាសញ្ញាដ៏ល្អបំផុត ដែល បង្ហាញដល់សុខភាពល្អនិងភាពស្តុក ស្តម្ភ។ មនុស្សប្រភេទនេះមានជីវិត ដែលគេចផុតពីការលំបាក។



www.elibraryofcambodia.org

មានខ្សែដែលខុសប្រក្រតីជាច្រើននៅលើតន្លាក់ម្រាមខាងក្រោមមេដៃ

បង្ហាញដល់ការគេចផុតពីបញ្ហារកប្រាក់នានា ថែមទាំងមានកេរ្តិ៍ឈ្មោះនិងលាភសំណាងដោយមិនពិបាកព្យាយាមទៀតផង។ មនុស្សប្រភេទនេះនឹងមានខ្សែជីវិតរឹងមាំខ្លាំងឡើង។





www.elibraryofcambodia.org

# ក្រចក

ក្រចកមិនត្រឹមតែបង្ហាញដល់សុខភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញដល់ឧបនិស្ស័យនិងលាភសំណាងទៀតផង។ ប្រភេទក្រចកដែលផ្តល់លាភសំណាងដល់មនុស្សច្រើនបំផុត គឺមានប្រវែងស្មើនឹងពាក់កណ្តាលទទឹងម្រាមដៃ ចំណែកសញ្ញាចំណិតព្រះចន្ទនៅជុំវិញក្រចក គួរមានប្រវែងស្មើនឹងមួយភាគប្រាំនៃប្រវែងក្រចក បើលេចឡើងនូវលក្ខណៈខុសពីរូបឬខូចខាតត្រង់កន្លែងណាមួយនៅត្រង់ក្រចក គឺជាការផ្តល់សញ្ញាថា មានជំងឺឈឺថ្កាត់ឬបញ្ហាសុខភាព។ ក្នុងករណីនេះ គួរប្រញាប់ទៅជួបគ្រូពេទ្យដើម្បីពិនិត្យសុខភាព។



ទ្រង់ទ្រាយនិងលក្ខណៈរបស់ក្រចកល្អ

នេះជាក្រចកដែលបង្ហាញដល់សុខភាពល្អ រាងកាយរឹងមាំ រួមទាំងចរិតស្មោះត្រង់ និងគួរឲ្យស្រឡាញ់។ មនុស្សប្រភេទនេះនឹងអាចទទួលបានជោគជ័យក្នុងអាជីព។



www.elibraryofcambodia.org

## ក្រចកវែង

អ្នកសិល្បៈនិងមនុស្សដែលមានអារម្មណ៍ទន់ជ្រាយច្រើនតែមានក្រចកវែង។ ពេលខ្លះ ពួកគេអៀនខ្មាសក្នុងសង្គមនិងអាចជាមនុស្សពូកែលាក់បាំងខ្លួន។ ពួកគេនៅមានបញ្ហាទាក់ទងនឹងសួតនិងកជាញឹកញាប់។



## ក្រចកខ្លី

បង្ហាញដល់គំនិតដ៏ឈ្លាសវៃនិងការពេញចិត្តលើការងារដើម្បីសម្រេចគោលដៅ។ ផ្ទុយទៅវិញ ពួកគេរឹងរូសដែលអាចធ្វើឲ្យអ្នកដទៃមិនចូលចិត្ត។ ក្រចកខ្លីថែមទាំងបង្ហាញដល់បញ្ហាទាក់ទងនឹងបេះដូង និងអាចកើតជំងឺបេះដូង។ នារីដែលមានក្រចកខ្លី ច្រើនតែមានបញ្ហាទាក់ទងនឹងស្បូន ដែលអាចធ្វើឲ្យកើតជំងឺគ្មានកូន។





www.elibraryofcambodia.org

### ក្រចកធំ



បង្ហាញដល់ចិត្តទូលំទូលាយចូលចិត្តធ្វើខ្លួនជាចំណុចរួមនៃចំណាប់អារម្មណ៍ និងពូកែទំនាក់ទំនង។ មនុស្សប្រភេទនេះចូលចិត្តធ្វើខ្លួនជាអ្នកធំ។ ទោះជាយ៉ាងណាក៏ដោយពួកគេអាចជឿទុកចិត្តលើខ្លួនឯងច្រើនពេក ពួកគេច្រើនតែជាមនុស្សរីករាយនឹងអ្វីៗជាច្រើន តែចុងក្រោយ ពួកគេអាចនឹងខ្វះកម្លាំងចិត្តក្នុងការធ្វើអ្វីផ្សេងៗ។

### ក្រចកតូច



ជាសញ្ញាបង្ហាញដល់ភាពភ្ញាក់រពឹកនិងការសម្រេចចិត្តមិនដាច់ស្រេច។ មនុស្សប្រភេទនេះសម្រេចចិត្តមិនបានថា គួរឆ្ពោះទៅទិសខាងណាល្អ។ ពួកគេអាចចាប់ផ្ដើមអ្វីផ្សេងៗដែលពូកែ តែខ្វះសមត្ថភាពដែលនឹងធ្វើវាឲ្យសម្រេច ហើយអាចបោះបង់វាចោលទៀតផង។



www.elibraryofcambodia.org

## ក្រចកមូល



បង្ហាញដល់ចិត្តទូលាយ យកចិត្តទុកដាក់និងមានភាពប៉ិន ប្រសប់បែបអ្នកការទូត ប៉ុន្តែអាច សម្រេចចិត្តមិនដាច់ស្រេច និងច្រើនតែ ផ្លាស់ប្តូរចិត្តជានិច្ច។ មនុស្សប្រភេទ នេះអាចទទួលបានជោគជ័យយ៉ាង ច្រើន បើស្គាល់ពីចំណុចខ្សោយរបស់ ខ្លួន ហើយធ្វើអ្វីមួយចំនួនទាក់ទងនឹង វា។ ការចងសម្ព័ន្ធមិត្តជាមួយនឹង មនុស្សដែលមានគោលបំណងនិងចិត្ត គំនិតរឹងមាំជាង នឹងអាចជួយពួកគេបាន។

## ក្រចកវែងនិងតូច



ជាសញ្ញារបស់មនុស្សមាន ឧត្តមគតិ ហើយជួនកាលមានការស្វែង យល់។ ពួកគេងាយនឹងខូចអារម្មណ៍និង ពិបាកយល់ចិត្តណាស់។ នារីដែលមាន ក្រចកបែបនេះ នឹងមានគ្រោងឆ្អឹងមិន រឹងមាំ និងគួរត្រួតពិនិត្យសុខភាពថា បាន ទទួលកាល់ស្យ៉ូមពីអាហារគ្រប់គ្រាន់ឬអត់។ ទាំងនេះដើម្បីចៀសវាងបញ្ហាពុកឆ្អឹង។



www.elibraryofcambodia.org

## ក្រចកបីជ្រុង



បង្ហាញដល់មនុស្សក្បត់ និងមនុស្សប្រពៃណេន ដែលអាចមានអាការៈផ្លូវចិត្តខុសប្រក្រតី ហើយអ្នកដទៃនឹងយល់ពីចិត្តរបស់មនុស្សប្រភេទនេះបានទាំងលំបាក។ ពួកគេអាចនឹងទទួលការលំបាកលើវិថីជីវិត។ មធ្យោបាយតែមួយ គឺលុបបំបាត់វិបត្តិនេះ ហើយព្យាយាមស្វែងយល់ដើម្បីអភិវឌ្ឍទស្សនៈក្នុងផ្លូវវិជ្ជមានឲ្យបានច្រើនឡើង។

## ក្រចកដែលមានខ្សែឈរនិងស្នាមតូចៗ



ជាសញ្ញាដែលអាក្រក់បំផុត គឺបង្ហាញដល់បញ្ហារំលាយអាហារ ដែលច្រើនតែនាំទៅរកការជក់បារីច្រើន។ មនុស្សពួកនេះគួរទៅប្រឹក្សាជាមួយនឹងពេទ្យដើម្បីពិនិត្យសុខភាព។



www.elibraryofcambodia.org

**ក្រចកដូចទឹករលក**

ចង្កុលបង្ហាញដល់បញ្ហាពោះវៀនតូច ជាញឹកញាប់ វាជាសញ្ញានៃការកើតឫសដូងបាត។



**ក្រចកដែលមានខ្សែឈរ**

នេះជាសញ្ញាបង្ហាញដល់សុខភាពមិនល្អមានអាការៈខាងប្រព័ន្ធប្រសាទ និងអាចមានជំងឺផ្លូវចិត្ត។ មនុស្សប្រភេទនេះនឹងបានទទួលប្រយោជន៍ ប្រសិនបើទៅជួបគ្រូពេទ្យឲ្យពិនិត្យសុខភាព។





www.elibraryofcambodia.org



### ខ្សែកដៃ
### ខ្សែកដៃបីឬច្រើនជាងនេះ

បង្ហាញដល់សុខភាពល្អនិងសំណាងល្អ បើខ្សែច្បាស់ល្អ វានឹងផ្ទុយពីនេះ។



### ខ្សែកដៃខាងលើកោង

បញ្ជាក់ដល់បញ្ហាប្រព័ន្ធបន្តពូជដែលច្រើនតែនាំទៅរកបញ្ហានៃការមានកូន។ មនុស្សប្រភេទនេះគួរទៅសុំការប្រឹក្សានឹងគ្រូពេទ្យ។



www.elibraryofcambodia.org

## មានសញ្ញាកាកបាទត្រង់ខ្សែកដៃ

១



ជាសញ្ញាដែលបង្ហាញដល់រយៈពេលដែលពិបាកក្នុងវ័យកំលោះក្រមុំ ទោះបីជាអ្វីផ្សេងៗនឹងផ្លាស់ប្ដូរទៅក្នុងផ្លូវដែលងាយសម្រាប់ពួកគេក្នុងវ័យដែលមានអាយុច្រើនក៏ដោយ នៅពេលវ័យចុងក្រោយនៃជីវិត ពួកគេនឹងមានស្ដុកស្ដម្ភ និងអាចជាមនុស្សដែលគេស្គាល់យ៉ាងទូលំទូលាយទៀតផង។

## ខ្សែកដៃដែលមើលទៅប្រហែលនឹងខ្សែច្រវ



បញ្ជាក់ដល់ចន្លោះពេលនៃការព្យាយាមនិងទន្ទឹងរង់ចាំឱកាសនៅខាងមុខ។ ពួកគេត្រូវធ្វើការច្រើនអស់មួយជីវិត ព្រោះជាសម្រាប់ពួកគេនឹងគ្មានថ្ងៃបានរបស់ទទេៗទេ។



www.elibraryofcambodia.org

### ផ្កាយមួយឬច្រើននៅលើខ្សែកដៃ



ជាសញ្ញាដែលល្អបំផុត គឺបង្ហាញដល់ការជួបនឹងលាភសំណាង ព្រមទាំងក្លាយជាមនុស្សស្ដុកស្ដម្ភអាចមានកេរ្តិ៍ឈ្មោះបានទៀតផង។

### ខ្សែកដៃរួមគ្នាជាសញ្ញាបីជ្រុងត្រង់គល់បាតដៃ



បញ្ជាក់ដល់ភាពជាមនុស្សស្ដុកស្ដម្ភនិងមានឈ្មោះបោះសំឡេង ដោយសារសមត្ថភាពនិងការធ្វើការច្រើន។ វាថែមទាំងជាសញ្ញាបង្ហាញដល់លាភសំណាងទៀតផង។



www.elibraryofcambodia.org

**ខ្សែកដៃបង្កើតជាសញ្ញាបីជ្រុង ដែលមានផ្កាយទៀតផង**

បញ្ជាក់ដល់ភាពស្មុកស្មាញនិងមានឈ្មោះបោះសំឡេង។ មនុស្សប្រភេទនេះនឹងទទួលបានជោគជ័យគ្រប់យ៉ាងដែលពួកគេជ្រើសរើសធ្វើ។





www.elibraryofcambodia.org

# អ្នកមានកេរ្តិ៍ឈ្មោះនិងបាតដៃរបស់ពួកគេ

**ឆាលីឆាភ្លីន** ( **សាក់ឡូ** ) កើតនៅក្រុងឡុងដ៍ ប្រទេសអង់គ្លេស ថ្ងៃទី ១៦ ខែមេសា ឆ្នាំ១៨៨៩។

**ឆាលីឆាភ្លីន** ( **សាក់ឡូ** ) តួសម្តែងនិងជាអ្នកដឹកនាំរឿង។ គាត់បានដឹកនាំនិងសម្តែងក្នុងភាពយន្តកំប្លែងកាយវិការជាច្រើន។ គាត់ច្រើនតែលេងជាមនុស្សអនាថា ជាតួសម្តែងដែលប្រៀបបានទៅនឹងសញ្ញាការលក់ ដែលទូទាំងពិភពលោកព្រមទទួលស្គាល់ ហើយនាំសំណើចឲ្យដល់មនុស្សរាប់លាននាក់។

ខ្សែខួរក្បាលរបស់សាក់ឡូកែងទៅនឹងខ្សែជីវិត ដែលទេរចុះទៅដល់ពកចន្ទ។ លក្ខណៈដូចនេះបង្ហាញដល់មនុស្សដែលមានក្តីស្រមៃខ្ពស់ ហើយមានចក្ខុវិស័យច្រើន។ គាត់ថែមទាំងមានខ្សែអាជីពដ៏រឹងមាំទៀតផង។ ខ្សែនេះសំដៅទៅរកម្រាមកណ្តាលនិងមានសញ្ញាបីជ្រុងត្រង់ចុងខ្សែនេះបញ្ជាក់ថា សាក់ឡូអាចធ្វើឲ្យក្តីស្រមៃភាគច្រើនក្លាយជាការពិត ហើយគាត់បាននាំយកភាពសប្បាយរីករាយមកចែកជូនដល់មនុស្សទូទាំងពិភពលោក។ ផ្ទុយទៅវិញ ខ្សែអាពាហ៍ពិពាហ៍មិនសូវមានរបៀប ដែលឆ្លុះបញ្ចាំងដល់សម្ពន្ធភាពដែលពោរពេញទៅដោយភាពរកាំរកូស។

**ថូម៉ាស់ អេឌ្វាអេឌីស៊ិន** កើតនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៨៤៧ ភូមិមីឡាន ( Milan ) សហរដ្ឋអាមេរិក។



www.elibraryofcambodia.org

**ថូម៉ាស់ អេលវ៉ាអេឌីស៊ិន** ជាអ្នកដាក់ទុនត្រង់ទៅត្រង់មក និងបានទទួលផលយ៉ាងច្រើនបំផុតក្នុងលោក ហើយមានកេរ្តិ៍ឈ្មោះយ៉ាងខ្លាំងពីការច្នៃប្រឌិតអំពូលភ្លើង ដែលផ្លាស់ប្តូរវិថីជីវិតប្រចាំថ្ងៃរបស់មនុស្សបានយ៉ាងច្រើន។

ខ្សែខួរក្បាលរបស់ អេឌីស៊ិន រឹងមាំនិងច្បាស់ បង្ហាញដល់សតិបញ្ញាខ្ពស់និងតម្រូវការស្រាវជ្រាវ។ ត្រង់កណ្តាលបាតដៃរបស់គាត់ មានសញ្ញាផ្កាយធំដែលបញ្ជាក់ដល់កេរ្តិ៍ឈ្មោះដ៏គួរឲ្យទទួលស្គាល់។

**អាល់ប៊ឺត អាញស្តាញ កើតនៅថ្ងៃទី១៤ ខែមិនា ឆ្នាំ១៨៧៩ នៅទីក្រុងអ៊ូលម៍**

**អាល់ប៊ឺត អាញស្តាញ** ជាអ្នកវិទ្យាសាស្ត្រផ្នែករូបវិទ្យាដ៏អស្ចារ្យបំផុតម្នាក់ក្នុងសតវត្សទី២០។ គាត់ជាមនុស្សដែលមានចក្ខុវិស័យទូលំទូលាយ និងមានសតិបញ្ញាខ្ពង់ខ្ពស់។ ទ្រឹស្តីសម្ពន្ធភាពរបស់គាត់បានអធិប្បាយថា កម្លាំងជុំវិញនិងចលនាឆ្លុះបញ្ចាំងចំពោះពេលវេលានិងអាកាសដូចម្តេចនោះ ត្រូវបាននាំយកទៅប្រើយ៉ាងទូលំទូលាយនៅបច្ចុប្បន្ន។

ខ្សែខួរក្បាលអាញស្តាញវែងនិងទេរចុះទៅដល់ពកចន្ទ។ នេះជាសញ្ញានៃក្តីស្រមៃនិងចក្ខុវិស័យ។ គាត់ថែមទាំងមានសញ្ញាបីផ្រុងដែលច្បាស់លើពកចន្ទទៀតផង ដែលបង្ហាញថា គាត់ច្រើនតែរកចម្លើយរបស់សំណួរផ្សេងៗជានិច្ច។ ត្រង់ក្រោមម្រាមនាងរបស់គាត់មានខ្សែតូចៗបីខ្សែ នេះជាសញ្ញានៃភាពជោគជ័យលើការងារ ហើយស្នាដៃរបស់គាត់ត្រូវគេទទួលស្គាល់ទូទាំងពិភពលោក។



www.elibraryofcambodia.org

# ភាគបន្ថែម

## ករណីសិក្សា

វិជ្ជាមើលបាតដៃរបស់ចិនត្រូវគេយកទៅប្រើយ៉ាងទូលំទូលាយអស់ជាច្រើនឆ្នាំមកហើយ។ មានការពិតមួយ គឺយើងអាចប្រើវាដើម្បីការពារមិនឲ្យកើតហេតុការណ៍ដែលនាំទុក្ខទោសមកដល់ខ្លួន។ ខ្ញុំយល់ថា ក្បួនមើលបាតដៃរបស់ចិនមានភាពជាក់លាក់ច្រើន នេះជាការអះអាងតាមរយៈអតិថិជនរបស់ខ្ញុំ។

ដូចមានករណីមួយ គឺស្ត្រីជនជាតិដាណឺម៉ាកម្នាក់មករកខ្ញុំដើម្បីសុំការទស្សន៍ទាយ។ នាងធ្វើការជាពេទ្យលើកប៉ាល (MS Scandinavian Star) ដែលធ្វើដំណើរទៅមករពីញូវយ៉កនិងដាណឺម៉ាក។ តាមរយៈបាតដៃរបស់នាង ខ្ញុំបានទាយថា នាងនឹងជួបបញ្ហាក្នុងពេលដ៏ខ្លី ហើយដោយសារនាងធ្វើការលើកប៉ាល់ ទើបខ្ញុំដាស់តឿនឲ្យនាងប្រយ័ត្នប្រយែង ហើយខ្ញុំអះអាងថា មិនថាមានអ្វីកើតឡើងទេ នាងអាចគេចពីវាបាន ហើយនាងក៏ចេញទៅ។

នៅទីបំផុត សប្តាហ៍នោះឯងក៏មានភ្លើងឆេះលើកប៉ាល់ខាងលើ ហើយស្ត្រីជនជាតិដាណឺម៉ាកម្នាក់នោះ គឺជាអ្នករួចផុតជីវិតម្នាក់ពីការទទួលរងគ្រោះ។ បន្ទាប់មក នាងក៏បានបង្ហើបប្រាប់ខ្ញុំថា អ្វីដែលខ្ញុំប្រាប់ដល់នាង គឺមានន័យសម្រាប់នាងណាស់ ហើយពាក្យសម្តីទាំងនោះឯងដែលធ្វើឲ្យនាងមានជីវិតរស់មកដល់សព្វថ្ងៃ។ ទោះបីជានាងត្រូវឈ្លក់នឹងផ្សែងភ្លើងនិងឧស្ម័នពេលកំពុងកើតហេតុការណ៍នោះក៏ដោយ តែនាងក៏បានព្យាយាមគ្រប់គ្រងសតិរហូតទាល់តែមានអ្នកជួយសង្គ្រោះ មកជួយនាងឲ្យរួចពីសេចក្តីស្លាប់បាន។



www.elibraryofcambodia.org

យើងខ្ញុំជាកូន ខ្មៅ យុនសំរ៉ែង ខ្មៅ យ៉ាតណៃ ខ្មៅសុខផល ខ្មៅ វិសាល ខ្មៅ រ៉ាមុន
ខ្មៅ ភារាជា ខ្មៅ ចំរើន ខ្មៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជា eBook
ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្មៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ ជិន ស្រីតូច

កក្កដា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការព្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្មៅ យុនសំរ៉ែង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

មានថ្ងៃណាមួយ
មនុស្សមួយចំនួននឹងឆ្លងកាត់
តាមរយៈខ្សែជីវិតរបស់យើង ដែលស្គាល់គ្នា
មកជាយូរគួរសម ប៉ុន្តែក៏នៅមិនដឹងជាតុពិតរបស់គេ
ដដែល ឬយើងគ្មានថ្ងៃអាចដឹងបានថា គេជាមនុស្ស
បែបណា? ដោយមើលតាមរយៈខ្សែស្នេហា
ខ្សែជោគជ័យ ខ្សែអាជីព ខ្នៅដៃ ឈ្នាងដៃ
ក្រចក ខ្សែត្រង់កដៃ។ល។
ដើម្បីឲ្យយើងចេះប្រយ័ត្នប្រយែងមុននឹង
សម្រេចចិត្តធ្វើអ្វីមួយក្នុងជីវិត។

ONLINE
IN TOUCH WITH YOUR WORLD
អ្នកផ្តល់សេវាអ៊ីនធើណែតឈានមុខគេនៅកម្ពុជា
The leading Internet Service & VoIP Provider in Cambodia
WWW.ONLINE.COM.KH

Find us at
facebook.com/ideabookpublishing

ISBN 978999-6332-24-1
9 789996 332241
៨ ០០០ រៀល

SI_224

www.elibraryofcambodia.org